សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

## កិច្ចបោះឆ្នោតបឋមនៅឡូវែល នឹងប្រព្រឹត្តទៅ នៅថ្ងៃទី ២៩កញ្ញា២០១៥

**The Lowell preliminary election will be on Tuesday, September 29, 2015.**

# សម្ដេចប៉ុបមកដល់សហរដ្ឋអាមេរិក

**រាយការណ៍និងដកស្រង់ព័ត៌មាន ដោយ ឆន យ៉ុង**

**ហ្វីឡាដែលហ្វៀ:** សម្ដេចប៉ូប ហ្វ្រង់ស៊ីស មេសាសនាកាតូលិក នៅវេទិកិននៃប្រទេសអ៊ីតាលីបានមកដល់សហរដ្ឋអាមេរិកជាលើកដំបូងនឹងជាប្រវត្តិសាស្ត្រទទួលនៅព្រលានយន្តហោះដោយប្រធានាធិបតីអាមេរិកាំង បារ៉ាក់ អូបាមា កាលពីថ្ងៃអង្គារទី ២២កញ្ញា បន្ទាប់ពីបានធ្វើទស្សនកិច្ច៤ថ្ងៃនៅប្រទេសគុយបាដែលជាប្រទេសកុម្មុនិស្ដមានទំនាក់ទំនងតិចតួចជាមួយស.រ.អា ។

នៅមុនពេលចុះពីយន្តហោះសម្ដេចប៉ូបបាននិយាយជាមួយអ្នកកាសែតថា លោកសង្ឃឹមថា សហរដ្ឋអាមេរិកនឹងដករនាំងសេដ្ឋកិច្ចចេញពីគុយបា តែមកទល់ពេលនេះលោក បារ៉ាក់ អូបាមា ពុំទាន់ទទួលបានការយល់ព្រមពីគណបក្សសាធារណរដ្ឋនៅឡើយ ។ សម្ដេចប៉ូប មិនមានបំណងនិយាយរឿងនេះ នៅវិមានរដ្ឋសភាអាមេរិកាំង ឬនៅវិមាន អ.ស.ប.នោះទេ តែគេរង់ចាំសម្ដេចប៉ូបនឹងនិយាយរឿងអន្តោប្រវេសន៍ជាមិនខាន។ គេនៅចាំបានថា **តទៅទំព័រទី០៤**



**ទស្សនៈសិក្សាធិការ**

## សាលារៀនកូន នៅតំបន់ដែលលោកអ្នករស់នៅ

## The schools of your Children

**ដោយ ពិន សំខុន**

គ្រួសារ៤-៥នាក់ ជជែកគ្នាអំពីអនាគតរបស់កូនទាក់ទងទៅនឹងការសិក្សា នាឱកាសបវេសនកាល២០១៥នៅឡូវែល ។ គិតតាំងតែពីថ្នាក់មតេយ្យ រហូតដល់ចប់មធ្យម



សិក្សា គឺជាកង្វល់ដ៏ធំធេងរបស់ឪពុកម្ដាយថា "សាលាណាមួយដែលអាចផ្ដល់ចំណូលចិត្តសិក្សានឹងចំណេះជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់សំរាប់ជោគជ័យនៃជីវិតរបស់កូនយើងម្នាក់ៗ"? យើងដឹងហើយថា នៅស្រុកនេះ គេមិនបង្ខំកូនឱ្យរៀនទេ គឺសាលាត្រូវរៀបចំរចនាសម្ព័ន្ធទទួលក្មេងឱ្យចូលចិត្តមករៀនសាលាខ្លួន។ ដូច្នេះយើងទៅស្ដាប់មាតាបីតា

**តទៅទំព័រទី ០៨**

**CENTURY PHARMACY & OPTICAL**

937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554

**ឱសថស្ថានសេនជូរី :**
យើងជា
អ្នកបំរើលោក
អ្នកយ៉ាងប្រសើរ!




- ផ្ដល់សេវាដល់ទីលំនៅ
- ខ្ចប់ឱសថតាមបំណង
- ជាឱសថស្ថានដែលលោកអ្នកអាចជឿជាក់ក្នុងចិត្ត

937 Gorham St Lowell, MA, 01852

**លេខទូរស័ព្ទ 978-455-6554 / លេខហ្វាក់ 978-455-9476**

## បុណ្យកាន់បិណ្ឌខ្មែរប៉ុស្ដិ៍ស.រ.អា

### យើងនឹងប្រារព្ធពិធីកាន់បិណ្ឌទី៥ នៅវត្តពន្លឺពុទ្ធចក្រ





នៅថ្ងៃសុក្រ ទី២ខែតុលា ឆ្នាំ២០១៥ ជួបជុំពុទ្ធបរិស័ទ
ស្ដាប់លោកសូត្រមន្ត ពីម៉ោង៥ល្ងាចថ្ងៃព្រហស្បតិ៍ទី១
ស្អែកឡើង ផ្ដើមបុណ្យម៉ោង៩ព្រឹក សូត្រមន្តប្រគេនចង្ហាន់
សូមបងប្អូន មាមីង តាយាយ
អញ្ជើញមកចូលរួមសាងកុសលតាមការគួរ
សូមទាក់ទង ពិន សំខុន 978-942-141

# CENTURY PHARMACY & OPTICAL

937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554

យើងជា ឱសថ ស្ថានមួយ ដែលអាចផ្តល់ ភាពជឿជាក់ ដល់គ្រួសារ លោកអ្នក




យើងខ្ញុំ សូមជូនពរ មហាប្រសើរ ដល់លោក អ្នក

- យើងខ្ញុំមានផ្តល់សេវាំបំរើការជូនឱសថដល់ទីលំនៅ ។
- យើងខ្ញុំទទួលកាតម៉ាសហ៊ាវ, និងកាតធានារ៉ាប់រង សុខភាពផ្សេងៗទៀត
- សេវាំបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
- យកចិត្តទុកដាក់លើបញ្ហាផ្ទាល់ខ្លួននៃអតិថិជនរាល់រូប ។
- វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
- មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
- យើងខ្ញុំទទួលការផ្សំថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។ ជាឱសថស្ថានមួយអាចផ្តល់ភាពជឿជាក់ដល់គ្រួសារអ្នក ។






យើងខ្ញុំនិយាយភាសាខ្មែរ ។

**លេខទូរស័ព្ទ 978-455-6554**

**លេខហ្វាក់ 978-455-9476**

## 937 Gorham St Lowell, MA, 01852

# ដំណើរវិស្សមកាលចុងក្រោយមុនចូលរៀន

## Last Vacation before Back to School ភាគ២



**ដោយ ពិន សំខុន**

នៅថ្ងៃទី៤នៃវិស្សមកាលយើង គឺជាថ្ងៃកំសាន្តរបស់ក្មេងៗ ។ នៅលើជ្រោយសមុទ្រដែលបានក្លាយទៅជាកោះដោយការជីកព្រែកផ្តាច់ "ដីចុងកណ្ឌៀវ" ឱ្យទៅជាកោះតែម្តងទីនោះបានផ្តល់នូវរមនីយដ្ឋានកំសាន្តដ៏ច្រើនមិនធ្វើឱ្យមនុស្សក្នុងតំបន់ ឬទេសចរអផ្សុកបានទេ គេបានសង់ជាកន្លែងកំសាន្តផ្នែកៗដែលទាំងក្មេងទាំងចាស់ចូលលេងល្បែងកំសាន្តបានច្រើនម៉ោង ម្លោះហើយទាំងអស់គ្នាតែចូលមកដល់ហើយមិនចង់ចេញទៅវិញទេ ។





មើលត្រីបាឡែនទាំងហ្វូងពីលើកប៉ាល់

ថ្ងៃទី៥របស់យើងពុំមានកម្មវិធីអ្វីច្បាស់លាស់ទេ ដូច្នេះដើម្បីបំពេញពេល១ថ្ងៃទៀតឱ្យក្មេងៗយើងក៏នាំគ្នាទៅស្រស់ស្រូបពេលព្រឹកនៅខាងក្រៅ ។ ប៉ុណ្ណារ៉ូ នឹងបងប្អូនជីដូនមួយគេចង់ទៅហាង"ដឹផេនខេកមេន The Pancake Man"ដែលពួកគេបង់តាំងពីមុនមួយថ្ងៃមកម្លេះ ។ ព្រឹកថ្ងៃសៅរ៍នោះ មានភ្ញៀវច្រើនណាស់មករង់ចាំតុអង្គុយនៅហាងអាហារនោះយើងមានសំណាងលើសអ្នកដទៃបន្តិច ពីព្រោះពេលមកដល់ពុំមានភ្ញៀវរង់ចាំកន្លែងអង្គុយនោះទេ" **តទៅទំព័រទី ០៥**


# វិជ្ជាស្ថានរៀនថែសម្ផស្សមុខនិងត្រចក

## Chelmsford Beauty Academy

**60 Chelmsford St.,2nd Floor Chelmsford, MA. 01824**

**Tel: (978)328-9722 ឬ (978) 250-4488**





- យើងខ្ញុំបានបើកវគ្គបង្រៀនធ្វើត្រចក និងថែសម្ផស្សមុខ គ្រូបង្ហាត់ មានការដកពិសោធន៍ច្រើនឆ្នាំ មានថ្នាក់រៀនក្រៅម៉ោង និងពេញម៉ោង៧ថ្ងៃក្នុង១សប្តាហ៍
- យើងខ្ញុំបើកវគ្គសិក្សា៣០០ម៉ោង (ក្នុងវេលា២ខែកន្លះ) សម្រាប់ថ្នាក់ថែសម្ផស្សមុខ និងវគ្គ១០០ម៉ោង (ក្នុងវេលា៣អាទិត្យ)
- សម្រាប់ថ្នាក់ធ្វើត្រចក ។
- សូមចុះឈ្មោះជាប្រញាប់ !
- (តម្លៃសិក្សាក្រចក ៩០០ដុល្លារ)
- (តម្លៃសិក្សាថែសម្ផស្ស ២៩០០ដុល្លារ)

**ជួយណែនាំរកការងារធ្វើពេលចប់ការសិក្សា**

Chelmsford Beauty Academy មានចម្ងាយ៥នាទីពីក្រុង Lowell, និង១៥នាទីពីក្រុង Lawrence, ចម្ងាយ១០នាទីពី Burlington Mall, និង១០នាទី Andover.

**ព័ត៌មានបន្ថែមទាក់ទងជាមួយយើងខ្ញុំថ្ងៃនេះតូរស័ព្ទលេខ : (978)328-9722 ឬលេខ : (978)250-4488**

# តមកពីទំព័រទី ០១ សម្ដេចប៉ូបមកដល់សហរដ្ឋអាមេរិក

វិហារកាតូលិកនៃសម្ដេចប៉ូបមិនយល់ស្រប នឹងគំនិតពន្យាកំណើតការពន្លូតកូននឹងរៀបការភេទដូចគ្នាទេ។

សម្ដេចប៉ូប នឹងទៅថ្លែងសុន្ទរកថា នៅវិមានអង្គការសហប្រជាជាតិថ្ងៃទី២៤ ស្របថ្ងៃដែលលោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន នៅទីនោះ



ដែរ... ទៅដល់ញូយ៉កថ្ងៃទី២៥ នឹងទៅដល់ហ្វីឡាដែលហ្វៀនៅថ្ងៃបន្ទាប់ក្នុងទស្សនកិច្ច៦ថ្ងៃរបស់សម្ដេចនៅសហរដ្ឋអាមេរិកនេះ។

តើសហគមន៍ខ្មែរនៅហ្វីឡាដែលហ្វៀដែលជាសហគមន៍ធំលំដាប់ថ្នាក់ទី៣ តើគេយល់យ៉ាងចំពោះវត្តមានសម្ដេចប៉ូបនេះ?

.លោក ម៉ម យីន ព្រឹទ្ធាចារ្យអាយុ៨២ឆ្នាំ រស់នៅតំបន់ខាងជើង និយាយថា លោកកាន់សាសនាគ្រឹះនេះតាំងពីមកដល់ឆ្នាំ១៩៨៣មក ហើយរក្សាជំនឿនេះក្នុងជីវិតរបស់លោក។



លោកបន្តថា សម្ដេច ប៉ូប គឺដូចជាសម្ដេចសង្ឃរាជរបស់សាសនាកាតូលិកតែលោកពុំមានភារកិច្ចទៅទទួលទេ ហើយក៏មិនចាប់អារម្មណ៍ដែរ ដោយសារមានជំនឿសាសនាមិនដូចគ្នាដោយលោកនៅក្នុងនិកាយ "ប្រូតេស្តង់"ទៅថ្វាយបង្គំព្រះរៀងរាល់អាទិត្យនៅវិហារដ៏ធំមួយ នាផ្នែកខាងត្បូងហ្វីឡាដែលហ្វៀ។

.លោក ហុង រ៉េន ជាសកម្មជនគណបក្សសង្គ្រោះជាតិនៅហ្វីឡាដែលហ្វៀលោកថា "ពិតមែនតែខ្ញុំកាន់សាសនាព្រះពុទ្ធខ្ញុំចង់ទៅទទួលសម្ដេចប៉ូបដែរតែមិនទាន់ដឹងថា ទៅទទួលរបៀបណានៅឡើយទេ សាសនាណាក៏មានគុណសម្បត្តិដែរ លើកលែងតែសាសនាម៉ូសលីម -កាលពីមុនលោកក៏ធ្លាប់ចូលក្នុងគ្រីស្ដសាសនាដែរនាសម័យនៅជំរំខាវអ៊ីដង"...។



.លោកស្រី ណយ យន ជាស្ថានិកបរិស័ទដំណឹងល្អខ្មែរនៅតំបន់ខាងជើងហ្វីឡាដែលហ្វៀមានប្រសាសន៍ប្រាប់ខ្មែរផុស្ដថា "សម្ដេច ប៉ូប ជាមនុស្សកំពូលនៃនៃអ្នកកាន់សាសនាកាតូលិកនៅក្នុងក្រុមជំនុំខ្មែរយើងពុំមានការទទួលសម្ដេចប៉ូបទេ ដោយយើងខ្ញុំជាគ្រីស្ដបរិស័ទគោរពលើព្រះយេស៊ូ រីឯសម្ដេចប៉ូបជាកាតលិកមានជំនឿលើម្ដាយរបស់ព្រះយេស៊ូ..."។



.នាង កនិដ្ឋា យ៉ុង ជាប្រជាពលរដ្ឋម្នាក់រស់នៅភាគខាងជើងនៃហ្វីឡាដែហហ្វៀ នាងយល់ថា ដោយសារសម្ដេចប៉ូបជាមេដឹកនាំសាសនាកាតលិកនាងនឹងមិនបានទៅទទួលស្វាគមន៍ទេ ក្នុងពិធីស្វាគមន៍ដ៏ធំរបស់សម្ដេចដែលគេសង្ឃឹមថា នឹងមានមនុស្សប្រមាណ១លាន៥នាក់ចូលរួមនោះទេ ដោយហេតុយល់ថា "នាងជាបរិស័ទខ្មែរគោរពលើព្រះអង្គម្ចាស់ពីព្រះយេស៊ូគ្រីស្ដ" នាងគ្មានជំនឿលើសម្ដេចប៉ូបនោះទេ។



សមាជិកសហគមន៍ខ្មែរមួយចំនួននៅហ្វីឡាដែលហ្វៀនៅប្រកាន់សាសនាយីស៊ូគ្រីស្ដដោយសារកាលពិពេលភៀស ខ្លួនមកដល់ជំរុំនៅប្រទេសថៃតាំងពី៣០ឆ្នាំមុន បាន ទទួលជំនួយពីលោកអាចារ្យ ហើយក៏បាន ចូលជាសមាជិកនៃសាសនាទាំងនោះទៀតផង...ហេតុនេះហើយបានជាគេឃើញមានវិហារណែអ្នកប្រកាន់សាសនាយីស៊ូគ្រីស្ដ ៤-៥កន្លែងនៅហ្វីឡាដែលហ្វៀដឹកនាំបង្ហាត់បង្ហាញរៀងរាល់អាទិត្យដោយគ្រូគង្វាលខ្មែរ ដូចលោកគ្រូ អ៊ូ តេង ជាដើម តែរស់នៅរួមជាមួយក្រុមខ្មែរឯទៀតៗដែលត្រឡប់មកកាន់ព្រះពុទ្ធសាសនាវិញ ក្នុងសហគមន៍បានយ៉ាងសុខសាន្ត៕






សូមថ្វាយបង្គំព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គជាទីសក្ការ: សូមគោរពគ្រូគង្វាល គ្រប់គណ: សូមគោរព លោកយាយ លោកតា អ៊ុំ ពូមីង ជាទីគោរព លោក លោកស្រី អ្នកនាងកញ្ញា ជាទីមេត្រី! **ថ្ងៃទី២៩ ខែកញ្ញា ២០១៥** ជាថ្ងៃប្រវត្តិសាស្ត្រសំរាប់ប្រជាពលរដ្ឋខ្មែររស់នៅក្នុងក្រុងឡូវែល ព្រោះវាជាថ្ងៃបោះឆ្នោតបឋមដែលបងបក្អូនខ្មែរនឹងចេញទៅបោះឆ្នោតជ្រើសរើសបេក្ខជនខ្មែរ ឱ្យធ្វើជាសមាជិកក្រុមប្រឹក្សាក្រុងឡូវែល ។ ប្រជាពលរដ្ឋម្នាក់មានសិទ្ធិបោះឆ្នោតឱ្យបេក្ខជនដល់ទៅ៩នាក់ ប៉ុន្តែលោកអ្នកអាចបោះឆ្នោតឱ្យតិចជាង៩នាក់ក៏បាន ។ គេធ្លាប់សួរខ្ញុំបាទថា តើហេតុអ្វីបានជាគាត់គួរបោះឆ្នោតឱ្យខ្ញុំ? ចម្លើយយ៉ាងខ្លីថា ខ្ញុំបាទមានការពិសោធន៍ក្នុងការជួយ ប្រជាពលរដ្ឋខ្មែរតាំងពីពេលដែលប្រជាពលរដ្ឋជនភៀសខ្លួនខ្មែរមកដល់សហរដ្ឋអាមេរិកដំបូង ដោយខ្ញុំបានទៅទទួលបងប្អូនពីវាលយន្តហោះ ចាត់ចែងឱ្យមានទីលំនៅ ចុះឈ្មោះ កូនចៅឱ្យចូលរៀន រកការងារឱ្យបងប្អូនធ្វើ ចេញមុខការពាសិទ្ធិប្រជាពលរដ្ឋខ្មែរដែលគេធ្វេបាប ជួយបងប្អូនដែលចង់ទិញផ្ទះ ឬបើកហាងជំនួញ ៕

# តមកពីទំព័រទី ០៣ ដំណើរវិស្សមកាលចុងក្រោយ...

យើងនាំគ្នាបញ្ចាម្ហូប "ផែនខេក" ស្រូបទឹកស្ករដ៏ឆ្ងាញ់ពីសារបានភ្លាមយ៉ាងរីករាយ ពីព្រោះអ្នកបំរើក្នុងហាងរៀបលំអដ៏ល្អស្អាតសម្រាប់ទាក់ទាញកុមារនោះ ចេះរាក់ទាក់នឹងចេះគួរសមភ្ញៀវណាស់។ ស្រស់ស្រូបហើយនៅសល់ពេលច្រើន យើងក៏នឹកគិតថា យកកម្មវិធីដែលត្រូវធ្វើ នាថ្ងៃស្អែកមកបំពេញល្ងាចនេះឱ្យហើយ ដូច្នេះត្រូវឡើងកាណូតទៅមើលសត្វសមុទ្រ ដូចជា "ត្រីបាឡែន whale" ជាដើម។ ដូច្នេះមុននឹងដល់ពេលចេញដំណើរទៅសមុទ្រនាម៉ោង៥ល្ងាច យើងនៅសល់ពេល៦ម៉ោងទៀត សម្រាប់ទស្សនាតំបន់ចុងប៉ូចបង្អស់នៃ "ខេបខត" គឺចុងបង្អស់នៃមុខកណ្ដៀវដែលមានឈ្មោះថា "ប្រវិនថោន Pronincetown" ឱ្យបានសម្រេច។ គឺទៅមន្ទីរទទួលទេសចរដែលទីនោះ ជាមណ្ឌលថែរក្សាដោយកងរក្សារសម្បត្តិធម្មជាតិពីដើមកន្លែងនោះ មានឈ្មោះថា "The Lifesavers of Cape Cod ឬអ្នកសង្គ្រោះជីវិតនៅ ខេបខត"។ មិនមានសំណង់អ្វីសំខាន់ទេ ពីព្រោះជាទីដែលថែរក្សាជីវិតរុក្ខជាតិនឹងគ្រប់សត្វរស់នៅជុំវិញតំបន់លើគោក និងក្នុងសមុទ្រផង តែពីទីនោះទៅគេអាចនាំគ្នាមើលទៅទីឆ្ងាយនៃសមុទ្រដ៏ល្អល្ហេវបាន ។ ពី "ប្រូវិនថោន" ម៉ោង៥រសៀលយើងនាំគ្នាឡើងកុប៉ាល់ឈ្មោះ DOLPHIN VIII សំដៅទៅឯនាយសមុទ្រទឹកជ្រៅតែមានទឹកហូរខ្លាំងនឹងរលកធំបង្គួរ ដើម្បីទៅមើលត្រីបាឡែន ។ ជិះកុប៉ាល់-កាណូត ដឹកភ្ញៀវប្រមាណ១៥០នាក់ ប្រហែលជាងកន្លះម៉ោងយើងមានក្ដីរំភើបនឹងបារម្ភណាស់ មុននឹងបានឃើញសត្វសមុទ្រដ៏ធំបង្អស់មួយៗហែលនៅក្បែរៗកុប៉ាល់យើងអ្នកដឹកនាំដំណើរនិយាយតាមមីក្រូពន្យល់ពីជីវិតសមុទ្រទឹកជ្រៅមិនមានចប់បន្តិចក្រោយមកទៅជួបនឹងបាឡែន ធំៗ ទំហំប៉ុនផ្ទះ ទាំងហ្វូង ជួនកាលមាន៥-៦ នាំទាំងគ្រួសារបាឡែនមានម៉ែឪនឹងកូនមកបង្ហាញខ្លួន ហើយមានឈ្មោះដែលគេអាចសំគាល់បានផង ដូចជាគេមកទទួលភ្ញៀវដែលមកលេងតំបន់ទឹកជ្រៅរបស់ខ្លួនខ្លះលោតបញ្ចេញខ្លួនទាំងមូល ខ្លះបញ្ចេញតែក្បាល ឬក៏តែកន្ទុយ ធ្វើឱ្យយើងចង់ឃើញពួកគេលែងភ័យព្រួយមិនចង់ឈប់។ ៣ម៉ោងក្រោយមកដល់ពេលត្រឡប់មកក្រោយក៏មិនចង់ឱ្យចប់ ពីព្រោះថ្ងៃលិចនៅ









សារមន្ទីរ កេណ្ណឌី

លើកុប៉ាល់ធំ DOLPHIN VIII បានផ្ដល់នូវទេសភាពចំរុះពណ៌ពាក់កណ្ដាលថ្ងៃនឹងយប់ពាក់កណ្ដាលសមុទ្រខៀវស្រងាត់នឹងជើងមេឃក្រហមព្រះអាទិត្យមូលពណ៌មាសលឿងទំនៅចំកណ្ដាល... បានកំណត់ជារូបភាពត្រកាលប្រចាំជីវិតថ្មីមួយទៀត មិនចង់ឱ្យឃ្លាតឡើយ ដោយសង្ឃឹមថាទស្សនីយភាពនៃថ្ងៃនេះ គឺជាចំណងដៃដល់ក្មេងៗដែលមកជាមួយឱ្យចងចាំថាជាព្រឹត្តិការណ៍កម្រនឹងពិសេសបំផុតរបស់ពួកគេ។

នៅថ្ងៃចុងបញ្ចប់នៃវិស្សមកាលរបស់យើង គឺស្វែងរកចម្លើយនៃលំអដែលទាក់ទាញប្រធានាធិបតីអាមេរិកាំងឱ្យមកឆ្លងធ្វើវិស្សមកាលនៅកោះ "ម៉ាតា Martha" ទីទល់មុខគ្នានេះ កាលពីឆ្នាំមុនៗនៅបានតែ១ថ្ងៃ ក៏កាត់វិស្សមកាលត្រឡប់ទៅដោះស្រាយបញ្ហាពិភពលោកជាបន្ទាន់ទៅវិញ។ យើងក៏បានឃើញភ្លាមថា នេះពុំមែនជាលើកទីមួយទេ ដែលតំបន់ "ខេបខត" បាននាំភ្ញៀវសហរដ្ឋអាមេរិកឱ្យមកមើលលំអខ្លួននោះទេ យើងបានទៅចូលទៅមើល "សារមន្ទីរ JFKennedy Museum" ទើបបានឃើញថា ទីនេះជាកន្លែងដែលសេចក្តីសម្រេចដ៏ធំៗបង្អស់ធ្លាប់បានធ្វើនៅទីនេះ ពីព្រោះជាភូមិកំណើតរបស់ប្រធានាធិបតីអាមេរិកាំង ជន កេណ្ណឌី មានឪពុក ម្ដាយ បង ប្អូនរស់នៅទីនោះ ។ ជាទីដែលលោកប្រធានាធិបតីកេណ្ណឌី នៃគ្រួសារបងប្អូន៩នាក់បានធ្វើការឃោសនាបោះឆ្នោតបានឈ្នះឆ្នោតជាប្រធានាធិបតីនាំបងប្អូនមួយចំនួនទៀតចូលដឹកនាំនយោបាយកំពូលបំផុត ហើយប្ដូរមុខមាត់នៃសហរដ្ឋអាមេរិកចេញពី "ខេបខត" នេះទៅ។

យើងបញ្ចប់ដំណើរនាថ្ងៃបន្ទាប់ប្រកបដោយអនុស្សាវរីយប្រសើរ ដើម្បីបវេស្សនកាលប៉ុណ្ណារ៉ូនឹងបងប្អូនជីដូនមួយគេ គឺ "វិរិយ៉ាន" នឹង "អជ្រៃ" ត្រឡប់ទៅចុលរៀននៅហ្វីឡាដែលហ្វៀវិញ ៕

adventures await

Greater Merrimack Valley
Convention & Visitors Bureau

For more fun things to see & do
and great places to eat & stay, visit...
www.merrimackvalley.org

SAVINGS WITH MASS APPEAL

DRIVERS WHO SWITCHED SAVED
$498
NATIONAL ANNUAL AVERAGE

**Want to save on car insurance? Call me first.**
It's time Massachusetts drivers had a better car insurance experience. I'll help you get the coverage that's right for you and the discounts you deserve. Call me today.



**Vanessa Dinh**
**781-547-6522**
665 Main Street
Waltham
vanessadinh@allstate.com

Allstate.
You're in good hands.

Savings based on national customer-reported data for new policies in 2012. Actual savings vary. Allstate Insurance Co. Northbrook, IL. © 2013 Allstate Insurance Co.

# គណកម្មការថ្មីនៃក្រុងខ្មែរ

**ដោយ : ខ្មែរផុសសរអា**

**ឡូវែល:** "ក្រុងខ្មែរ"ដែលមានកំណើតនាកណ្តាលក្រុងឡូវែលមានភារៈកិច្ចរៀបចំថែលំអរ តាមទំនៀមទម្លាប់នឹងវប្បធម៌ខ្មែរក្នុងតំបន់ដ៏សម្បូរខ្មែររស់នៅច្រើនបំផុត ឯជ្រោយ





ខាងកើតសហរដ្ឋអាមេរិក ហើយកំពុងប្រែប្រួលយ៉ាងសកម្មស្របតាមទស្សនៈជាតំបន់សេដ្ឋកិច្ចអាស៊ីដ៏ធំមួយ ។ គណកម្មការគ្រប់គ្រង "ក្រុងខ្មែរ"នេះត្រូវបានជ្រើសតាំងសាជាថ្មី បន្ទាប់ពីបញ្ចប់អាណត្តិ២ឆ្នាំរបស់គណកម្មការលោក សេងលី គង់ កាលពីថ្ងៃទី១៣កញ្ញា ឆ្នាំ២០១៥។ គណកម្មការនាយកមានគ្នា៩រូប បានជ្រើសរើសអ្នកស្រី លក្ខិណា ផល្លី ជាប្រធានក្រុងខ្មែរ អាណត្តិ២ឆ្នាំថ្មីទៀត ហើយបានរៀបចំតែងតាំងគណកម្មការប្រតិបត្តិដែលមានលោក តុលា យុទ្ធ ជាអនុប្រធាន វដ្ឋា ខៃ ជាលេខាធិការ និងអ្នកស្រី សុភក្រ្តា ណារ៉ា ជាហិរញ្ញិក ។

អ្នកស្រីប្រធាន លក្ខណា ផល្លី បាននិយាយថា "ដោយសារខ្ញុំធ្លាប់ជាអ្នកសិល្បៈខ្ញុំចង់បានក្រុងខ្មែរឱ្យក្លាយជាក្រុងដែលមានខ្មែររួបរួមគ្នាជាធ្លុងមួយជុំវិញវប្បធម៌របស់យើង - សម្រាប់២ឆ្នាំទៅមុខទៀតនេះ គណកម្មការក្រុងខ្មែរនឹងផ្តោតអារម្មណ៍ទៅលើការសាងសង់រូបចម្លាក់ព្រហ្មបាយ័ននៅលើដីច្រមុះជ្រូក នៅមុខហាង "ប៉ៃលិន" ជាមុនគេបង្អស់ ពីព្រោះមានបញ្ហាច្រើនណាស់ ហើយរីឯគម្រោងផ្សេងៗទៀត នឹងគិតនៅពេលក្រោយទៀត ៕

# គម្រោងថ្មីនៃការដាក់រូបចម្លាក់ព្រហ្មបាយ័ននៅក្រុងខ្មែរ

**ឡូវែល:** កាលពី៤ខែមុន គណកម្មការក្រុងខ្មែរបានឱ្យសាធាណៈជនដឹងថា ក្រសួងវប្បធម៌កម្ពុជានឹងធ្វើអំណោយរូបចម្លាក់ព្រហ្មបាយ័នធ្វើពីថ្មភ្នំ កំពស់២ម៉ែត្រឱ្យទៅគណកម្មការក្រុងខ្មែរក្រុងឡូវែលសម្រាប់ដាក់តាំងនៅតំបន់ច្រមុះជ្រូក "ប៉ៃលិនប្លាហ្សា" តែដំណឹងមួយទៀតលេចឮថា អំណោយនោះ ពុំមែនជារបស់ក្រសួងវប្បធម៌ទេ តែជាអំណោយរបស់កូនប្រុសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឈ្មោះ ហ៊ុន ម៉ាណែត ជាឧត្តមសេនីយទោនៃកងទ័ពជាតិទៅវិញ ។ ដំណឹងចុងក្រោយបានឱ្យដឹងទៀតថា លោក ហ៊ុន ម៉ាណែត នឹងប្រគល់ព្រហ្មបាយ័ននោះទៅថ្វាយព្រះ-មហាក្សត្រ ដើម្បីឱ្យព្រះអង្គជាអ្នកប្រគល់រូបចម្លាក់នោះមកឱ្យ "ក្រុងខ្មែរ" ជំនួស។

ប្រជាពលរដ្ឋបញ្ញាវន្តខ្មែរនៅឡូវែលពេលឮដំណឹងនេះភ្លាមមានការខឹងសម្បារនឹងថ្នាក់ដឹកនាំក្រុងខ្មែរដែលហ៊ានយក

តទៅទំព័រទី១១








# REMEDIUM PHARMACY

2 VINAL Square
N. Chelmsford, MA 01863

Phone: (978) 251-7070

## FREE Daily Home Delivery



**Blisterpack Packaging**

**Friendly Consultations**

**Compounded Medications**

**Easy Transfers**

បុគ្គលិកទាំងអស់របស់ឱសថស្ថានរីមីឌីមយើងខ្ញុំមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបំរើសេវាផ្តល់ឱសថជូនដល់សហគមន៍ខ្មែរ។ គេទាំងអស់គ្នាបានត្រៀមរួចជាស្រេចដើម្បីជួយ និង ត្រៀមបំរុងជានិច្ច ដើម្បីប្រើគ្រប់ជំនាញ និងការពិសោធន៍ក្នុងការបំរើលោកអ្នក។




ឱសថស្ថានរីមីឌីម ផ្តល់ជូនលោកអ្នកនូវៈ
ជូនឱសថឲ្យដល់លំនៅស្ថានដោយឥតគិតថ្លៃ
ដាក់ឱសថក្នុងបន្ទះបែងចែកឱសថសំរាប់ប្រើតាមពេល
ការពិគ្រោះយោបល់យ៉ាងរាក់ទាក់ស្និទស្នាល
មានផ្តល់ជូនម្សៅថ្នាំលាយ
ភាពងាយស្រួលក្នុងការផ្ទេរចេញចូល



Cristina គ្រីស្ទីណាៈ
គ្រីស្ទីណាមានការពិសោធន៍គ្រប់គ្រាន់នៅក្នុងកិច្ចការបំរើសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង៣ឆ្នាំមកហើយ។អ្នកស្រីគឺជាឱសថការិនីដែលគ្រប់គ្រងឱសថស្ថាន រីមីឌីម នេះ ហើយគាត់ក៏អាចធ្វើការពិគ្រោះអំពីឱសថ ជូនលោកអ្នកដល់ផ្ទះផងដែរ។ ដោយសារការផ្តល់នូវសេវាកម្មផ្នែកឱសថនេះ បានច្បាស់លាស់ទើប អ្នកស្រីអាចបង្កើត បាននូវចំណងមិត្តភាពយ៉ាងល្អប្រពៃក្នុងសហគមន៍ខ្មែរក្នុងក្រុងឡូវែល ហើយអ្នកស្រីមានសេចក្តីរីករាយណាស់ដើម្បីរង់ចាំបំពេញនូវបំណងរបស់លោកអ្នកដែលត្រូវការឱសថ។



Pahim លោកប៉ាហ៊ីមៈ
គឺជាបុគ្គលម្នាក់ដែលមានការគោរពច្រើននៅក្នុងសហគមន៍ខ្មែរ គាត់ក៏ជាសមាជិកម្នាក់នៅក្នុងគណកម្មការវត្តត្រៃរតនារាម ហើយធ្លាប់មានការពិសោធន៍ជាច្រើនឆ្នាំក្នុងការជួយសហគមន៍ដែលត្រូវការព្យាបាលជម្ងឺ។ ក្នុងរយៈកាលកន្លងមក គាត់ធ្លាប់បានធ្វើការយ៉ាងច្រើនជួយគាំទ្រដល់អ្នកជម្ងឺនៅមជ្ឈមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែលនិងមណ្ឌលសុខភាពពេទ្យមេត្តា ព្រមទាំងធ្លាប់បានចូលរួមចំណែកក្នុងការថែទាំដោយឱសថសំរាប់សហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង២ឆ្នាំផងដែរ។ ក្នុងនាមជសមាជិកម្នាក់នៃឱសថស្ថានរីមីឌីម គាត់នឹងបន្តធ្វើការបំរើឱ្យកាន់តែខ្លាំងខ្លាថែមទៀតដើម្បីបំពេញនូវតំរូវការក្នុងការផ្តល់ឱសថដល់លោកអ្នក។



Dary ដារីៈ
តែងបានយកចិត្តទុកដាក់ជាប់ជានិច្ចក្នុងសេវាកម្មផ្តល់ឱសថ ដើម្បីបំពេញតាមតំរូវការនៃសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈជាង២ឆ្នាំមកហើយ ហើយតែងទទួលបាននូវការកោតសរសើរពីសំណាក់អតិថិជនដែលបានជួបប្រាស្រ័យជាមួយគាត់។ ក្នុងឋានៈជាអ្នកបច្ចេកទេសម្នាក់របស់ឱសថស្ថាន គាត់មានការយល់ដឹងយ៉ាងជ្រៅជ្រះអំពី តំរូវការ និងប៉ិនប្រសប់ក្នុងការផ្តល់សេវាជូនលោកអ្នកនិងចេះសំដែងនូវការគោរពយ៉ាងទន់ភ្លន់ចំពោះលោកអ្នកផងដែរ។



Kelly ខែលលីៈ
គឺជាឱសថការិនីយើងដែលអាចនិយាយភាសាខ្មែរហើយដែលយកចិត្តទុកដាក់ចេះជួយលោកអ្នក។ គាត់ជាឱសថការិនី ចេញពីមហាវិទ្យាល័យឱសថសាស្ត្ររដ្ឋម៉ាសាឈូសេត និង ពេញចិត្តធ្វើការបំរើសហគមន៍ខ្មែរដែលគាត់ក៏ជាសមាជិកម្នាក់នៃសហគមន៍នេះដែរ។



Daniela ដានីញែលឡាៈ
មានជំនាញច្បាស់លាស់ក្នុងការវេចខ្ចប់ឱសថដាក់ក្នុងបន្ទះពង្រាយថ្នាំសំរាប់ប្រើតាមពេល ហើយធ្លាប់ឆ្លងកាត់ការថែទាំអ្នកជម្ងឺខ្មែរដែលរស់នៅក្នុងក្រុងឡូវែលនេះអស់រយៈពេលជាង៣ឆ្នាំមកហើយ។ ប្រសិនបើលោកពេញចិត្តនឹងការប្រើថ្នាំដាក់ក្នុងបន្ទះបែបនេះ ដានីញែលឡាពេញចិត្តណាស់នឹងធ្វើកិច្ចការនេះជូនលោកអ្នក។



Kassandraកាសាន់ដ្រាៈ
គឺជាបុគ្គលិកដែលមានការពិសោធន៍ច្រើនក្នុងការធ្វើទំនាក់ទំនងជាមួយសហគមន៍ខ្មែរ និងស្បានិសសដែលរស់កក្នុងងក្រុងឡូឡូវែលលនេះ។
លោកអ្នកអាចនឹងពេញចិត្តអំពីភាពរាក់ទាក់រាល់ពេលនិយាយឆ្លើយឆ្លងតាមទូរស័ព្ទជាមួយនាង និងប៉ិនប្រសប់ក្នុងការរៀបចំឱសថជូនលោកអ្នកនៅរាល់ពេលដែលលោកអ្នកត្រូវការ។

## តមកពីទំព័រទី ០១ សាលារៀនកូននៅតំបន់ដែលលោកអ្នក...

នឹងគ្រូបង្រៀនពិគ្រោះគ្នា តើគេនិយាយពីសាលារៀនយ៉ាងណា?

• នៅឡូវែលយើងនេះ នារីម្នាក់មានហាងលក់នុំខេកនៅកណ្តាលក្រុង តែផ្ទះនាងនៅ "ដ្រេខិត" បាននិយាយថា ខ្ញុំចូលចិត្តទៅនៅ ដ្រេខិត ពីព្រោះតែចង់បានសិទ្ធឱ្យកូនទៅរៀនសាលាល្អ តែបើការកស៊ីវិញ ខ្ញុំចូលចិត្តធ្វើការនៅឡូវែលជាងដោយសារសម្បូរខ្មែរច្រើន។

• លោកគ្រូម្នាក់នៅឡូវែលនិយាយថា ខ្ញុំចង់បានឱ្យកូននៅរៀនសាលាសាធារណ ពីព្រោះតែមានគ្រូល្អៗសុទ្ធតែ "ស៊ើទីហ្វាយ Certified" ហើយរៀងរាល់២-៣ខែម្តង គេបញ្ជូនឱ្យគ្រូៗទៅបំពេញវិជ្ជាបន្ថែម ឬបង្រ្កប់លើអ្វីដែលគេយល់ថា មានការខ្វះខាត ។ ដូច្នេះមានការធានាថា មានគ្រូល្អៗសម្រាប់កូនខ្ញុំបានជាពិសេសឥតមានបង់លុយថ្លៃសាលាឱ្យកូនរៀនទេ។

• ឪពុកក្មេងម្នាក់មានតួនាទីជានាយកការិយាល័យនិយាយថា ខ្ញុំនៅ "ធិកប៊ូរី" ពីព្រោះចង់បានសាលាដែលមានការដឹកនាំខ្ពស់ឱ្យកូន។ មានកូនដល់ទៅ៣នាក់ កូនខ្ញុំទៅរៀនសាលាសាធារណមានគុណភាពខ្ពស់ចំណេញជាងនៅឡូវែលដែលកូនត្រូវរៀននៅសាលាឯកជន ទើបបានលទ្ធផលល្អ។

• អ្នកគ្រប់គ្រងព្រះវិហារ ឈើជ នៅឡូវែលម្នាក់និយាយថា ខ្ញុំមានផ្ទះនៅ "ធិកប៊ូរី" ដោយ



សារសាលានៅទីនោះមានកំរិតខ្ពស់កូនរៀននៅគ្រេដទី៨ សាលាសាធារណខាងនោះ មានចំណេះស្មើនឹងគ្រេដទី១១សាលាសាធារណឡូវែលទៅហើយ នេះមកពីឡូវែលជាតំបន់ចំរុះសាសន៍ រៀបចំកំរិតសាលាតាមកំរឹតវប្បធមិកូនសិស្សដែលមកដល់ថ្មីជាច្រើនក្នុងតំបន់នេះជាហេតុដែលនាំឱ្យកំរឹតសិក្សាធ្លាក់ទាប។

• ប៉ូលីស អហ្វីស័រ ខ្មែរម្នាក់នៅឡូវែល មានកូន២នាក់ បានឆ្លងផុតទៅមហាវិទ្យាល័យល្អៗអស់នៅឆ្នាំនេះ គាត់បាននិយាយថា សូមមើលកូនអ្នកមាន ឬមនុស្សសំខាន់ៗនៃឡូវែល! គេបញ្ជូនកូនគេទៅរៀនសាលាឯកជន ឬចេញក្រៅឡូវែល ដើម្បីឱ្យបានទទួលការសិក្សាអាចទៅឆ្ងាយបាន។ ខ្ញុំចំណាយពេលគ្រប់យ៉ាងសម្រាប់ការអប់រំកូនខ្ញុំបើកុំតែបញ្ជូនទៅសាលាឯកទេសនៅក្រៅឡូវែលទាន់ពេលប្រហែលជាយ៉ាប់។

មិនដូចខ្មែរយើងកាលពីនៅស្រុកមិនបានណែនាំកូនអ្វីក្រៅពីប្រគល់កូនទៅឱ្យសាលារៀន




នោះទេ ដូចពាក្យជាទូទៅតែងឧទ្ទាន "ថាសូមលោកគ្រូទុកតែភ្នែកនឹងឆ្អឹងឱ្យខ្ញុំវិញបានហើយ"។ នៅសហរដ្ឋអាមេរិកនេះ គេយកចិត្តទុកដាក់កូនចៅខុសពីទំនៀមទំលាប់យើងខ្លាំងណាស់ ទំនៀមទំលាប់ថ្មីម្តាយឪពុក គឺជាដៃគូរអប់រំកូនពេលនៅសាលារៀនយ៉ាងជិតស្និតជាមួយនឹងគ្រូបង្រៀនកូនចៅរៀនអន់ គឺមិនត្រឹមតែគ្រូទេជាអ្នកខុស សូម្បីតែឪពុកម្តាយ ឬអាណាព្យាបាលក៏ចូលរួមខុសជាមួយគ្នាដែរ។ ឪពុកម្តាយគឺជាអ្នកចូលរួមពេញទំហ៊ឹងមើលតាមដានការវិវត្តន៍វិស័យសិក្សាគ្រប់នាទីរបស់កូនខ្លួន ហើយត្រូវទៅចូលរួមប្រជុំជាមួយគ្រូច្រើនដង ក្នុងមួយឆ្នាំផង។

កូនចៅខ្មែរនៃជំនាន់ទី២-ទី៣ បានក្លាយទៅជាឪពុកម្តាយខ្លួនឯងទៅហើយ ដូច្នេះកង្វល់ចំពោះការអប់រំកូនចៅនេះ គឺជាបញ្ហាដ៏ចំពោះរបស់ពួកគេហើយ ពីព្រោះពួកគេបានជួបប្រទះរឿងនេះ ដោយផ្ទាល់ខ្លួនដោយធ្លាប់រងគ្រោះដោយមាតាបិតាខ្លះ រវល់ខ្វល់នឹងមុខរបរចិញ្ចឹមជីវិតទុកដាក់ការអប់រំកូនចៅពេលនោះជារឿងបន្ទាប់បន្សំ ក៏ប៉ុន្តែក៏នៅមានកុមារនឹងយុវជនជាច្រើននៅឡើយ កំពុងទទួលការអប់រំនៅឡូវែលក្នុងបច្ចុប្បន្ននេះ។

សហគមន៍ខ្មែរ នៅឡូវែល ឬប្រូវិដិន ឬ លីនរីវែ ឬ ហ្វីឡាដែលហ្វៀ គួរពិគ្រោះគ្នាឱ្យបានច្រើនពីកំរឹតកម្មវិធីសិក្សារបស់សាលារៀន នាតំបន់និមួយៗជម្រុញរដ្ឋបាលក្រុងជម្រុញគណកម្មការសាលារៀនឱ្យប្រឹងប្រែងកែរកម្មវិធីសិក្សាតម្លើងគុណភាពឱ្យបានខ្ពស់បានន័យថា សម្រួលការសិក្សារឱ្យក្មេងចង់ទៅរៀនឱ្យគ្រូបង្រៀនមានទេពកោសល្យប្រើកម្មវិធីទំនើបធ្វើឱ្យការប្រៀបធៀបមិនចាញ់ដាច់ឆ្ងាយពីកម្មវិធីសិក្សានៃក្រុងដ៏ទៃនៃសរអាបាន។

មានបេក្ខជនខ្មែរ៤នាក់ឈរឈ្មោះជាបេក្ខជនទីប្រឹក្សាក្រុងឡូវែលនឹងខ្មែរ២នាក់ទៀត ឈរឈ្មោះជាបេក្ខជនគណកម្មការសាលារៀនឡូវែលនឹងបេក្ខជនសាសន៍ផ្សេងទៀត ដែលស្រឡាញ់សហគមន៍ឡូវែល ហើយចង់លើកដំកើងការសិក្សារបស់កុមារនឹងយុវជនខ្លួន ដូច្នេះសូមបង្ហាញជំហ៊ានចំពោះបញ្ហានេះឱ្យបានច្បាស់លាស់ បើនរណាមិនគាំទ្រ ឬក៏គាំទ្រមិនគ្រប់គ្រាន់ទេ សូមកុំគូសឈ្មោះឱ្យជាប់ឆ្នោតធ្វើអ្វី...តែផ្ទុយទៅវិញ បើបេក្ខជនណាមានយោបល់ច្បាស់លាស់ពីការលើកដំកើងសិក្សាធិការកំរិតមតេយ្យកំរិតបឋមនឹងកំរិតមធ្យមសិក្សា គួរតែយកចិត្តទុកដាក់បោះឆ្នោតឱ្យបេក្ខជននោះឱ្យបានច្រើនមិនថាអ្នកនោះជាសាសន៍អ្វីនោះទេ៕






# More benefits. $0 cost.

If you are 65 or older and qualify for MassHealth Standard, our plan could get you more benefits than Original Medicare.

With **UnitedHealthcare® Senior Care Options (HMO SNP)**, your doctor, hospital and prescription drug coverage are all under one convenient card.

Plus, you'll get extra benefits — at no cost to you. These extra benefits include:

- **$0 co-pay** for dental cleanings, fillings, dentures and more.
- **$0 co-pay** for all covered medications.
- **$0 co-pay** for eyewear.
- **$0 co-pay** for rides to doctor appointments.



Call **1-781-888-7779, TTY 711,** and one of our local, licensed agents can help you find out if you could get more benefits at no cost to you.

UnitedHealthcare® Community Plan

UnitedHealthcare SCO is a Coordinated Care plan with a Medicare contract and a contract with the Commonwealth of Massachusetts Medicaid program. Enrollment in the plan depends on the plan's contract renewal with Medicare. This plan is a voluntary program that is available to anyone 65 and older who qualifies for MassHealth Standard and Original Medicare. If you have MassHealth Standard, but you do not qualify for Original Medicare, you may still be eligible to enroll in our MassHealth Senior Care Option plan and receive all of your MassHealth benefits through our SCO program. The benefit information provided is a brief summary, not a complete description of benefits. For more information contact the plan. Limitations, co-payments and restrictions may apply. Benefits, formulary, pharmacy network, provider network, premium and/or co-payments/co-insurance may change on January 1 of each year. Premiums, co-payments, co-insurance and deductibles may vary based on the level of Extra Help you receive. Please contact the plan for further details. Enrollees have no out of pocket costs.

H2226_150326_160615 Accepted
UHCSCO_150326_160615

CST8162



# ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

## សិទ្ធិធ្វើបាតុកម្មមាន សុំមិនឲ្យ ធ្វើបង្ក្រាប តើឲ្យពលរដ្ឋដើរផ្លូវណា?

មាត្រា៣៧នៃរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្នចែងថា ពលរដ្ឋខ្មែរមានសិទ្ធិធ្វើកូដកម្ម និងបាតុកម្មដោយសន្តិវិធី។ ពេលពលរដ្ឋសុំហែធ្វើបាតុកម្មដោយសន្តិវិធី អាជ្ញាធរ ពិសេសក្រសួងមហាផ្ទៃតែងនិយាយថា មិនអនុញ្ញាត ព្រោះខូចសណ្តាប់ធ្នាប់សាធារណៈ ស្ទះចរាចរណ៍ ពលរដ្ឋខ្មែរគ្មានជម្រើសក៏ចាប់ធ្វើ អាជ្ញាធរក៏ចាប់បង្ក្រាប ដោយចោទថាបាតុកម្មគ្មានច្បាប់។ សុំមិនឲ្យធ្វើបង្ក្រាបតើឲ្យពលរដ្ឋដើរផ្លូវណា?ដាក់កំហុសទៅលើពលរដ្ឋជានិច្ច។ ការបង្ក្រាបមានពេលខ្លះប្រើហិង្សាធ្វើឲ្យពលរដ្ឋត្រូវរបួសរហូតស្លាប់ក៏មាន។ ប្រទេសកាន់របបប្រជាធិបតេយ្យ គេគ្រាន់តែជូនដំណឹងពុំមែនសុំអនុញ្ញាតទេ អាជ្ញាធរគេក៏ចាត់អ្នករក្សាសន្តិសុខឲ្យរក្សារបៀបរៀបរយតាមទំហំបាតុកម្ម។ អំពីការចាប់បាតុករដាក់ពន្ធនាគារដោយចោទថាប្រើអំពើហិង្សា។ តាមសាក្សីឃើញនឹងភ្នែក អំពើហិង្សាតែងកើតមានពីអាជ្ញាធរផ្តើមមុន ហើយអាចមានបាតុករខ្លះទ្រាំមិនបានវាយតបវិញដើម្បីការពារខ្លួន។ កាលគណបក្សសង្គ្រោះជាតិធ្វើបាតុកម្មអហិង្សាជិតមួយឆ្នាំគ្មានកើតហេតុអ្វីឡើយ ព្រោះអាជ្ញាធរមិនបង្ក្រាប។ ដូច្នេះ ការកាត់ទោសសកម្មជនគណបក្សសង្គ្រោះជាតិជាង១០នាក់ ជាការខុសច្បាប់ ត្រូវតែដោះលែងដោយគ្មានលក្ខខណ្ឌ។

មាត្រា៤០នៃរដ្ឋធម្មនុញ្ញចែងថា ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងរូបបុគ្គល ត្រូវធ្វើឲ្យស្របនឹងបញ្ញត្តិច្បាប់។ ដូច្នេះ កាលដែលអាជ្ញាធរក្រុងភ្នំពេញចុះឆែកឆេរព្រះសង្ឃវត្តមុនីរង្សីវត្តខ្មែរកម្ពុជាក្រោមដោយគ្មានដីកាពីតុលាការ ជាការខុសច្បាប់។មាត្រា៣៨ចែងថា ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។ដូច្នេះ យុវជន៣រូបជាចលនាមាតាធម្មជាតិនៅខេត្តកោះកុងប្រឆាំងនឹងក្រុមហ៊ុនវៀតណាមដែលបូមខ្សាច់ធ្វើឲ្យបាក់ដីខូចបរិដ្ឋាន បានត្រូវអាជ្ញាធរចាប់ឃុំគម្រាមកំហែង ជាការចាប់ខុសច្បាប់ ត្រូវតែដោះលែង។

វត្តខ្មែរកាណាដា,ថ្ងៃ១៩កញ្ញា២០១៥;www.hoksavannhok;savannhok@yahoo.com




Chetra A. Keo, D.C.

**Clemente Park Chiropractic**

851 Middlesex Street. Lowell, MA 01851

**(978) 937-1492**

**Treatments**

- Neck Pain — ឈឺ-ក
- Back Pain — ឈឺខ្នង
- Lower Back Pain — ឈឺចង្កេះ-ខ្នង

- Automobile Injuries — គ្រោះថ្នាក់រថយន្ត
- Personal Injuries — រងរបួស
- Work Related Injuries — របួសនៅកន្លែងធ្វើការ

WE ARE EXPANDING!
យើងនឹងបើកកន្លែងថ្មីមួយទៀត!

New Location in Lynn Opening in October!
383 Chestnut St. Lynn, MA 01904



**Vote Dan Rourke for City Council on Tuesday, September 29**



សមាជិកក្រុមប្រឹក្សា ដន រូក ថតជាមួយ សូ សុភក្រ្ត នៅហាង
កែសម្ផស្ស សូ សុភក្រ្ត ផ្លូវ មីឌុលសិច

**បោះឆ្នោតឱ្យ ដន រូក ជាក្រុមប្រឹក្សាក្រុង**
**ថ្ងៃអង្គារ៍ ទី២៩ កញ្ញា**

ធ្លាប់ជាប់ឆ្នោតពីខែវិច្ឆិការ២០១៣នៅក្រុមប្រឹក្សាសាលាក្រុង ដង រូក តែងតែបានបំរើក្រុងឡូវែល

- ដឹកនាំការប្រឹងប្រែង ក្រុមជំនួយដំបូងជាមួយនឹងណេខាន ដើម្បីប្រយុទ្ធនឹងវិបត្តគ្រឿងញៀន
- ណែនាំឱ្យមានការងារធ្វើដល់អ្នករស់នៅក្នុងតំបន់ពីការងារសំណង់របស់ក្រុង
- ធានាថវិការុករកក្រុមប្រើគ្រឿងផ្ទុះជាប្រព័ន្ធ
- ធានាឱ្យមានប្រព័ន្ធផ្លូវបង្ហូរទឹកបន្ទាប់ពីពេលមានធ្លាក់ព្រិលជាប្រវត្តិសាស្រ្តមក

*"ជាម្ចាស់ហាងពាណិជ្ជកម្មខ្នាតតូច ខ្ញុំមានសោមនស្សនឹងការខិតខំប្រឹងមិនចេះនឿយហត់របស់ ដន ដើម្បីបង្កើនសេដ្ឋកិច្ចក្នុងតំបន់ ហើយនឹងរក្សាសុវត្ថិភាពសហគមន៍។ ដន បាន បង្ហាញស្នាដៃគ្រប់ពេល នឹងប្រាកដជាផ្តល់លទ្ធផលថ្មីទៀតនៅឡូវែលគ្រប់គ្នា"* **សូ សុភក្រ្ត**

Paid for and Authorized by the Committee to Elect Dan Rourke —15 Bridget Lane, Lowell, MA 01854

# អាហារ ៣ ប្រភេទ ជួយបន្ថយខ្លាញ់ពោះលឿនបំផុត

អាថិកំបាំងបញ្ចុះទម្ងន់ពុំស្ថិតនៅតែនឹងការគិតគូរល្អិតល្អន់បរិមាណកាឡូរីស្រូបយកប្រចាំថ្ងៃប៉ុណ្ណោះទេ តែនៅពាក់ព័ន្ធជិតស្និទ្ធដល់ការជ្រើសរើសអាហារឈ្លាសវៃ ។ មានអាហារផ្ទុកកាឡូរីតិច, ថាមពលច្រើន តែពុំទាន់ប្រាកដបានជួយអ្នកបញ្ចុះទម្ងន់ ។ ផ្ទុយមកវិញ មានប្រភេទអាហារដែលអ្នកគិតថាមិនសមស្របសម្រាប់របបហូបតមបែរជាជំនួយដល់ការបញ្ចុះទម្ងន់លឿនជាង ។ អាហារ ៤ ប្រភេទខាងក្រោមនេះ ត្រូវបានចាត់ទុកជាអាហារមាសជួយអ្នកបញ្ចុះខ្លាញ់ពោះជោគជ័យ ។

**១-ត្រី:** ប្រសិនរបបទទួលទានរបស់អ្នកខ្វះ Omega-៣-សារជាតិជីវជាតិមានច្រើននៅក្នុងត្រី, សរីរាង្គនឹងជួបបញ្ហាក្នុងការផលិត melatorin - អ័រម៉ូនសំខាន់ជួយឱ្យអ្នកគេងលក់ស្រួល ។ គេងមិនលក់ធ្វើឱ្យអ្នកមាននិន្នាការបរិភោគកំប៉ិកកំប៉ុកច្រើនជាងនៅពេលយប់ ។ ត្រីនៅសម្បូរប្រូតេអ៊ីនអាចបំពេញភាពឃ្លានរបស់អ្នក ។ បន្ថែមលើនោះ ទទួលទាន Omega-៣ ច្រើនអាចបង្កើនសុខភាពសរសៃឈាមបេះដូង និងបន្ថយហានិភ័យកើតជំងឺសរសៃប្រសាទ ។

**២-ពពួកគ្រាប់:** ពពួកគ្រាប់ដូចជាអាល់ម៉ុន, ស្វាយចន្ទី, សណ្តែកដី.... សម្បូរសារជាតិជីវជាតិ តែមិនបង្កការផ្តុំខ្លាញ់ ។ អ្នកអាចជ្រើសយកវាធ្វើជាអាហារសម្រន់, គួបផ្សំជាមួយផ្លែឈើ, យ៉ាអួ ក្នុងរបបហូបតមរបស់ខ្លួន ។

**៣-ទឹកដោះគោ:** មនុស្សជាច្រើន ភាន់ច្រឡំថា ទទួលទានទឹកដោះគោច្រើនធ្វើឱ្យធាត់ ។ ប៉ុន្តែការស្រាវជ្រាវ១របស់អ្នកវិទ្យាសាស្ត្រអង់គ្លេសបង្ហាញថា ក្នុងចំណោមស្ត្រីជាង១០០នាក់ ក្នុងដំណាក់កាលមុនអស់រដូវ, ជាតិខ្លាញ់បានថយចុះច្រើននៅអ្នកប្រើប្រាស់ពពួកអាហារសម្បូរកាល់ស្យូមបំផុត ។

## តមកពីទំព័រទី ០៦ គម្រោងថ្មីនៃការដាក់រូបចម្លាក់...

ឈ្មោះក្រុងឡូវែលទៅសុំអំណោយរដ្ឋាភិបាលភ្នំពេញ ពួកគេបាននិយាយថា "ប្រជាពលរដ្ឋខ្មែរក្រណាស់ហើយមិន គួរឱ្យរដ្ឋាភិបាលចំណាយលុយរដ្ឋមកធ្វើអំណោយដល់ក្រុងខ្មែរទេ ខ្មែរក្រុងឡូវែលក៏មានសមត្ថភាពគ្រប់គ្រាន់នឹងសាងសង់រូបព្រហ្មដោយខ្លួនបានដែរ" ។ លោក សេងលី គង់ ពេលនោះជា


កន្លែងបំរុងដាក់រូបព្រំបាយន្ត

ប្រធានបានប្រកែកថា "ពុំមានធ្វើគម្រោងនោះដោយចិត្តឯងទេ មានមនុស្សក្នុងសហគមន៍បានចុះហត្ថលេខាគាំទ្រជាង ៦០០នាក់" តែរឿងនោះ បន្ទាប់មកក៏បានស្ងាត់ស្ងៀមទៅវិញ ពុំមានដំណឹងអ្វីថ្មីថារឿងរូបចម្លាក់នោះ មានដំណើរ ឬក៏ជាប់គាំងត្រង់ណារហូតដល់ពេលនេះ ។

សាកសួរអ្នកស្រី លក្ខិណា ផល្លា ប្រធានក្រុងខ្មែរ ទើបនឹងជាប់ឆ្នោតថ្មីថ្មោង កាលពីថ្ងៃសៅរ៍ទី១៧កញ្ញាកន្លងទៅនេះ នៅហាងកាហ្វេថ្មីរបស់អ្នកស្រីដែលទើបសម្ពោធបានមួយសប្តាហ៍ស្រាប់តែដំណឹងបានផ្លាស់ប្តូរអស់ពាក់កណ្តាលរួចទៅហើយ ។ អ្នកស្រីបាននិយាយថា "គម្រោងសង់ព្រហ្មបាយ័ននៅតែបន្ត...ប៉ុន្តែពុំមែនជាអំណោយរបស់អ្នកណាផ្សេងពីស្រុកខ្មែរទៀតទេ គឺជាស្នាដៃរបស់ខ្មែរទាំងអស់នៅទីក្រុងឡូវែលនេះ :

១-ប្លង់នៃរូបចម្លាក់ព្រះព្រហ្មមុខបួនឱ្យ គេគូរសារជាថ្មីតូចជាងគំរូមុនបន្តិចដោយសារទីកន្លែងតូចជាងមុនគូរប្លង់ជា២ដង អស់ប្រាក់៣៥០០ដុល្លា

២-ម្ចាស់ដីគេនឹងចុះហត្ថលេខាឱ្យប្រើប្រាស់ដីច្រមុះជ្រូកសម្រាប់ដំកល់រូបចម្លាក់នោះ ចំនួន៩៩ឆ្នាំ

៣-បានបង់ប្រាក់កក់៥ពាន់ដុល្លាឱ្យទៅជាងចម្លាក់ផ្តើមធ្វើរូបចម្លាក់នៅកម្ពុជារួចហើយ ក្នុងតម្លៃជិត៣ម៉ឺនដុល្លារ នឹងថ្លៃដឹកជញ្ជូនជាងមួយម៉ឺនដុល្លារថែមទៀត

៤-ផ្តើមធ្វើបុណ្យផ្កាប្រមូលបច្ច័យជាលើកដំបូងនោះ វត្តថ្មី"សាមគ្គីសន្តិការាម" ថ្ងៃទី២៧ កញ្ញាខាងមុខនៅធិងប៊ូរ៉ូ ហើយសូមបងប្អូនអញ្ជើញចូលរួមឱបានកុះករ ។

យើងបានធ្វើការសង្កេតថា ការផ្លាស់ប្តូរគម្រោងការណ៍នេះ បានធ្វើទៅតាមមតិសហគមន៍ដែលថា ចង់ឃើញស្នាដៃក្រុងខ្មែរជារបស់ខ្មែរនៅឡូវែលនឹងដោយសាររូបចម្លាក់ព្រហ្មបាយ័នមានការគាំទ្រច្រើនគ្នាគ្មាននរណាជំទាស់ចង់ដាក់រូបផ្សេងនៅទីនោះទេ ៕


# ជីម ឡេរី - ក្រុមប្រឹក្សាក្រុងឡូវែល
## Jim Leary – Lowell City Council

សិក្សាធិការ: ផ្តល់ថវិកាដើម្បីឱ្យគុណភាពសិក្សាធិការប្រសើរឡើង
សេដ្ឋកិច្ច: អភិវឌ្ឍន៍ពាណិជ្ជកម្មក្នុងតំបន់ បង្កើនចំណូលពន្ធមូលដ្ឋាន អាចយកមកបំរើសេវាផ្សេងៗ
ពង្រឹង: សុវត្ថិភាពក្នុងតំបន់

ខ្ញុំសូមឲ្យបងប្អូនបោះឆ្នោតឲ្យខ្ញុំ១ ក្នុងចំណោម៩រូប
នៅថ្ងៃបោះឆ្នោតបឋម
នាថ្ងៃអង្គារ៍ ទី២៩ កញ្ញា ២០១៥



BA Westfield State College
Lowell School Committee 10 years – Chairman of the Finance Subcommittee
Former member of the Lowell Taxi and Livery Commission
Member – Lowell Elks
Member – East End Club

# គុណសម្បត្តិ និងគុណវិបត្តិនៃត្រកួនដែលស្ត្រីមេផ្ទះគួរតែដឹង

ត្រកួនគឺជាបន្លែពណ៌បៃតងដែលក្រុមគ្រួសារជាច្រើនចូលចិត្តបរិភោគស្ទើរតែរៀងរាល់ថ្ងៃ។ ត្បិតតែត្រកួនផ្តល់នូវអត្ថប្រយោជន៍ជាច្រើនក៏ពិតមែន ប៉ុន្តែវាអាចមានគ្រោះថ្នាក់ដក់សុខភាពផងដែរ។



**គុណសម្បត្តិ**

ត្រកួនជាបន្លែដែលមានវីតាមីន និងសារធាតុរ៉ែដូចជា ជាតិសរសៃ ប្រូតេអ៊ីន កាល់ស្យូម ជាតិដែក វីតាមីន A និងវីតាមីន C។ ប្រភពនៃជាតិដែកនៅក្នុងត្រកួន គឺជាប្រភពអាហារពណ៌បៃតងសម្រាប់ដ៏មានភាពអស្ចារ្យសម្រាប់មនុស្សស្លេកស្លាំង និងស្ត្រីមានផ្ទៃពោះ។ មិនតែប៉ុណ្ណោះ វាក៏មានឥទ្ធិពលបញ្ចុះលាមករំលាយអាហារ និងមានប្រសិទ្ធិភាពជាមួននឹងការទល់លាមក។ ចំពោះមនុស្សដែលសន្លប់ដោយសារតែទទួលរងនូវកម្តៅខ្លាំងពេកអាចប្រើទឹកដែលផ្សំពីបន្លែមួយប្រភេទនេះជាមួយអំបិល ឬក្រូចឆ្មាជួយឱ្យរាងកាយធ្វើសំយោគយ៉ាងឆាបរហ័ស។

ជាតិប្រូតេអ៊ីនខ្លះនៅក្នុងត្រកួនដែលបន្លែជាច្រើនទៀតមិនមានដូចជា lysine, tryptophan, threonine, valine, leucine... ទាំងនេះគឺជាអាស៊ីតអាមីណូដែលចាំបាច់សម្រាប់រាងកាយ ជួយឱ្យមនុស្សឈឺមានការសុខភាពល្អប្រសើរឡើងវិញ និងអ្នកដែលខ្វះប្រូតេអ៊ីន។ វាក៏អាចជួយគាំទ្រដល់ការការពារ និងការព្យាបាលនៃជំងឺទឹកនោមផ្អែម។

**គុណវិបត្តិ**

ពពួកនៃប៉ារ៉ាសិតជាច្រើនអាចជ្រាបចូលទៅក្នុងរាងកាយយ៉ាងងាយស្រួល ប្រសិនបើអ្នកបរិភោគទាំងឆៅ ឬក៏លាងមិនបានស្អាតល្អ។ ប្រភេទនៃប៉ារ៉ាសិតទាំងនេះអាចការពារខ្លួនឯងដោយភ្ជាប់ខ្លួនទៅនឹងជញ្ជាំងពោះវៀន និងបង្កឱ្យមានបញ្ហារំលាយ អាឡែហ្ស៊ី ការឈឺពោះ។ ប្រសិនបើមិនដោះស្រាយឱ្យទាន់ពេលចេះតែបណ្តែតបណ្តោលយូរទៅវាអាចបង្កឱ្យមានផលវិបាកធ្ងន់ធ្ងរដល់ស្លាប់។ លើសពីនេះទៅទៀតដោយសារតែត្រកួនមានការរីកលូតលាស់លឿនមិនថានៅកន្លែងណា ឬរដូវណានោះទេក៏វាអាចរស់បានដែរ។ បច្ចុប្បន្ននេះអ្នកដាំត្រកួនមួយចំនួនតែងតែប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតដើម្បីថែរក្សាត្រកួន និងការប្រមូលផលមិនត្រឹមត្រូវទាំងនេះគឺជាហានិភ័យដ៏គួរឱ្យព្រួយបារម្ភចំពោះសុខភាព។ ក្រសួងសុខាភិបាលបានផ្តល់អនុសាសន៍ថាកសិកម្មស្លឹកត្រកួនសម្បូរទៅដោយជាតិមីច្រើនជាងគេ អាចបណ្តាលឱ្យពុលកម្រិតខ្ពស់។ ដូច្នេះការប្រើប្រាស់បន្លែដែលមានសំណល់ថ្នាំសំលាប់សត្វល្អិតសើសលុបធ្វើឱ្យអ្នកបរិភោគពុលរ៉ាំរ៉ៃប្រព័ន្ធភាពស៊ាំចុះខ្សោយ ហើយប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទថែមទៀត។

**ការប្រើប្រាស់បន្លែឱ្យមានសុវត្ថិភាព**

ដើម្បីធានាបាននូវសុខភាពសម្រាប់ក្រុមគ្រួសារទាំងមូលអ្នកត្រូវយកបន្លែទៅលាងជាមួយនឹងទឹកស្អាត ឬក៏ត្រាំក្នុងទឹកអំបិលជាមុនសិនមុនពេលចម្អិន។ ប្រសិនបើអ្នកចង់ទុកប្រើនៅពីរបីថ្ងៃបន្តទៀត សូមវេចខ្ចប់ដាក់ក្នុងទូកទឹកកឱ្យបានល្អវាអាចជួយរក្សាបន្លែមិនឱ្យឆាប់ខូចបាន៕

On September 29th,

Please VOTE **Rodney Elliott - #15 on Ballot**

Leadership - Courage -
Committed to the Community



*Mayor Rodney Elliott*

នៅថ្ងៃអង្គារ៍ ទី២៩ កញ្ញា

-សូមអញ្ជើញទៅបោះឆ្នោតឱ្យ **រ៉តនីយ អេលីយ៉ុត**

**គំនិតដឹកនាំ ក្លាហាន បំរើសហគមន៍**

ក្នុងពេលដែលខ្ញុំនៅជាអភិបាលក្រុង ខ្ញុំបានជួបមនុស្សល្អៗជាច្រើន នៅក្នុងសហគមន៍ខ្មែរ
- ខ្ញុំបានធ្វើដំណើរទៅកម្ពុជា - ខ្ញុំបានធ្វើការលើរូបចម្លាក់ថ្មសម្រាប់ដាក់នៅសាលាក្រុងជូនប្រជាពលរដ្ឋខ្មែរ
- ខ្ញុំបានទៅវត្តដើម្បីគាំទ្រទាំងអស់គ្នានាឱកាសមានអគ្គីភ័យនៅ"ប្រេនស្ទ្រីត"
- ខ្ញុំចង់នៅជាមួយ និងជួយសហគមន៍ខ្មែរតទៅទៀត។

# MARCOTTE LAW FIRM
## ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្ដីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្ដឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ

**មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ**

(978) 458-1229

www.marcottelawfirm.com



# ប៉ាន សូ - #14 on Ballot
## បេក្ខជនក្រុមប្រឹក្សាក្រុងឡូវែល
**Pan so - Lowell City Councilor Candidate**



**គោលបំណង:** សូមបងប្អូនបោះឆ្នោតឱ្យខ្ញុំ ដើម្បីឱ្យខ្ញុំបានបំរើសហគមន៍ៈ ប្រកបដោយភាពជាដំណាងមតិសហគមន៍-បង្កើតកម្មវិធីបណ្ដុះបណ្ដាលការសិក្សាឱ្យកូនចៅបានចំណេះខ្ពង់ខ្ពស់-ពង្រឹងគណកម្មការមុខរបរដើម្បីបង្កើតការងារបន្ថែម-ធ្វើការជាមួយរដ្ឋាភិបាលដើម្បីពង្រឹងសន្តិសុខ-ចូលរួមគណកម្មការក្រុងឡូវែលនឹងក្រុងជិតខាងដើម្បីមិត្តភាពនឹងរីកចំរើន ។

**ករិតសិក្សានឹងវិជ្ជាជីវៈ** មានសញ្ញាប័ត្រវិស្វករអេឡិចត្រូនិក-អនុបណ្ឌិតគ្រប់គ្រងមុខជំនួញ-រៀនពីរឆ្នាំនៅសាលាច្បាប់-សញ្ញាប័ត្រគ្រូបង្រៀននៅវិទ្យាល័យ២៩ឆ្នាំ នឹងមានប័ណ្ណសរសើរជាគ្រូបង្រៀនប្រចាំឆ្នាំ-

ជាអតីតនាយទាហ៊ានជំនាន់ទី២៩ អ្នកនិពន្ធសៀវភៅ "From Genocide to Freedom..."



# រីតា មើស៊ីយៀ
## នៅថ្ងៃទី ២៩ ខែកញ្ញា ២០១៥

លោកអ្នកមានឱកាសនឹងបញ្ចេញមតិ
នៅលើសិទ្ធជាមូលដ្ឋានដ៏សំខាន់មួយ
គឺ "សិទ្ធបោះឆ្នោត"

សូមអញ្ជើញបោះឆ្នោតឱ្យខ្ញុំ ជាថ្មីម្ដងទៀត
បោះឆ្នោតឱ្យលេខ៤
Rita M. Mercier
លេខ៤ នៅហិបឆ្នោត ។
សូមអរគុណ!

On Tuesday, September 29th, you have the opportunity to express one of your most basic rights, "The right to vote"

Please,
Vote for me once more
Vote for #4



Rita M. Mercier
#4 on the ballot.
Thank you.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# កម្ពុជាជាប់ឈ្មោះជាប្រទេសដែលមានអត្រាបាត់បង់ព្រៃឈើលឿនបំផុតនៅក្នុងពិភពលោក

**ដោយហ្សមប៊ រ ភីធើរ** | September 16, 2015

យោងតាមតួលេខសកលថ្មីដែលផ្អែកលើទិន្នន័យផ្កាយរណបរបស់សហរដ្ឋអាមេរិកឱ្យដឹងថា ការបាត់បង់ព្រៃឈើក្នុងប្រទេសកម្ពុជាចន្លោះពីឆ្នាំ២០០១ដល់ឆ្នាំ២០១៤? មានអត្រាលឿនជាងប្រទេសណាៗទាំងអស់នៅក្នុងពិភពលោក។

យោងតាមតួលេខបញ្ចេញនៅខែនេះដោយវិទ្យាស្ថានធនធានពិភពលោក (World Resources Institute) ហៅកាត់ WRI ដែលមានមូលដ្ឋាននៅក្នុងរដ្ឋធានីវ៉ាស៊ីនតោន? ដោយផ្អែកលើទិន្នន័យប្រមូលដោយសាកលវិទ្យាល័យម៉ារីលែន (University of Maryland) និងក្រុមហ៊ុនហ្គូហ្គល (Google) ដោយប្រើប្រាស់រូបភាពផ្កាយរណបបានបង្ហាញថា អត្រាប្រចាំឆ្នាំដែលកម្ពុជាបានបាត់បង់គម្របព្រៃឈើរបស់ខ្លួនក្នុងរយៈពេល១៤ឆ្នាំមកនេះបានកើនឡើង១៤.៤ភាគរយ។

លោក ម៉ែស្ទូ ហ៊ែនសិន (Matthew Hansen) ដែលបានដឹកនាំការសិក្សាស្រាវជ្រាវរបស់សាកលវិទ្យាល័យនេះ? បានលើកឡើងតាមអ៊ីម៉េលថា "ជារួមកម្ពុជានៅតែមានអត្រាខ្ពស់ជាងគេបំផុត"។

ប្រទេសសៀរ៉ាឡេអូន បានជាប់ចំណាត់ថ្នាក់លេខ២ ដោយកើនឡើង១២.៨ភាគរយ បន្ទាប់មកគឺប្រទេសម៉ាដាហ្គាស្កា អ៊ុយរូហ្គាយ និងប៉ារ៉ាហ្គាយ។ ប្រទេសលីបេរីយ៉ា ហ្គីណេ ហ្គីណេប៊ីស្សូ វៀតណាម និងម៉ាឡេស៊ី ស្ថិតនៅក្នុងចំណាត់ថ្នាក់កំពូលទាំង១០។

វិទ្យាស្ថាននេះបានលើកឡើងថា ទិន្នន័យថ្មីបំផុតនេះបានរកឃើញ "ការកើនឡើងគួរឱ្យព្រួយបារម្ភ" នូវការបាត់បង់ព្រៃឈើនៅក្នុង "តំបន់ក្តៅ" ចំនួន៤ជុំវិញពិភពលោកដោយក្នុងនោះរួមមានទាំងអាងទន្លេមេគង្គផងដែរ។

លោកបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍មួយអមដោយទិន្នន័យថ្មីនេះថា "ជាមួយនឹងប្រព័ន្ធផ្កាយរណប Landsat ដែលអាចផ្តល់ការគ្របដណ្តប់ទូទាំងពិភពលោករាល់៨ថ្ងៃម្តង ធ្វើឱ្យយើងមានសមត្ថភាពមិនធ្លាប់មាននៅក្នុងការឃ្លាំមើលការប្រែប្រួលព្រៃឈើទូទាំងសាកលលោក។ ទិន្នន័យស្តីពីការបាត់បង់គម្របព្រៃឈើឆ្នាំ២០១៤ដែលដាក់បញ្ចូលរូបភាពឡានដសាតរាប់សែនសន្លឹកបញ្ជាក់ថា ការកាប់បំផ្លាញព្រៃឈើនៅក្នុងប្រទេសនានាមិនត្រឹមតែខ្ពស់ទេ ពោលគឺវាកំពុងតែបង្កើនល្បឿនទៀតផង។ ជំហានបន្ទាប់គឺត្រូវប្រើប្រាស់ព័ត៌មាននេះដើម្បីពង្រឹងការការពារព្រៃឈើ និងធ្វើឱ្យការអភិវឌ្ឍសេដ្ឋកិច្ចកាន់តែមានតុល្យភាពរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងសេវាធម្មជាតិដ៏មានតម្លៃដែលព្រៃឈើផ្តល់ឱ្យ"។

មន្ត្រីក្រសួងកសិកម្ម និងមន្ត្រីរដ្ឋបាលព្រៃឈើមិនអាចទាក់ទងសុំការបំភ្លឺបានទេ។

ការឃ្លាំមើលព្រៃឈើសកល (Global Forest Watch) ដែលជាកម្មវិធីមួយរបស់វិទ្យាស្ថានធនធានពិភពលោកនិយាយថា កម្ពុជា បានបាត់បង់ព្រៃសរុប១.៤៤លានហិកតា ឬ ១៤.៤៧១ គីឡូម៉ែត្រក្រឡានៃព្រៃឈើចន្លោះពីឆ្នាំ២០០១ដល់ឆ្នាំ២០១៣។ នោះបានធ្វើឱ្យកម្ពុជាជាប់ចំណាត់ថ្នាក់លេខ២៣ក្នុងពិភពលោកសម្រាប់ការបាត់បង់គម្របព្រៃឈើសរុប ហើយជាប់លេខ៩ ជាចំណែកនៃគម្របព្រៃឈើដែលប្រទេសកម្ពុជាមាននៅក្នុងឆ្នាំ២០០០។

វិទ្យាស្ថានធនធានពិភពលោកមិនបានផ្តល់គម្របព្រៃឈើសរុបដែលកម្ពុជា បានបាត់បង់នៅក្នុងឆ្នាំ២០១៤នោះទេ។ យោងតាមអង្គការសិទ្ធិមនុស្សលីកាដូ ដែលបានវិភាគទិន្នន័យផ្កាយរណបផ្តល់ដោយសាកលវិទ្យាល័យម៉ារីលែន បានឱ្យដឹងថា កម្ពុជាបានបាត់បង់ប្រហែល១៥៦.០០០ហិកតានៃគម្របព្រៃកាលពីឆ្នាំមុន។

ទន្ទឹមនឹងនេះ? យោងតាមការវិភាគរបស់អង្គការលីកាដូលើទិន្នន័យនេះបានឱ្យដឹងថាជិត១ភាគ៣នៃគម្របព្រៃឈើដែលកម្ពុជាបានបាត់បង់កាលពីឆ្នាំមុនបានបាត់ព្រៃក្នុងតំបន់ការពារ។

តទៅទំព័រទី២៣

# Cambodia Sees World's Fastest Acceleration of Forest Loss

**BY ZSOMBOR PETER | SEPTEMBER 16, 2015**

Forest loss in Cambodia between 2001 and 2014 accelerated at a faster rate than in any other country in the world, according to new global figures based on U.S. satellite data.

The annual rate at which Cambodia lost its tree cover over the past 14 years increased 14.4 percent, according to figures released this month by the Washington-based World Resources Institute (WRI) based on data compiled by the University of Maryland and Google using the satellite images.



Blue shows areas of tree cover loss in 2014. Yellow, orange and red show areas in which tree cover was lost between 2000 and 2013. (University of Maryland)

"Cambodia is still the highest overall," Matthew Hansen, who led the university's research, said in an email.

Sierra Leone came in second at 12.8 percent, followed by Madagascar, Uruguay and Paraguay. Liberia, Guinea, Guinea-Bissau, Vietnam and Malaysia round out the top 10.

The Institute said the latest data identified an "alarming surge" in forest loss in four "hotspots" around the world, including the Mekong River Basin.

"With the Landsat satellite system capable of delivering global coverage every eight days, we have an unprecedented ability to monitor global forest change," Mr. Hansen said in a statement accompanying the new data.

"The 2014 tree cover loss data, incorporating hundreds of thousands of Landsat images, confirms that deforestation is not just high in certain countries, it's speeding up," he said.

"The next step is to use this information to improve forest protection and more equitably balance economic development with the invaluable ecosystem services forests provide."

Officials at the Ministry of Agriculture and its Forestry Administration could not be reached for comment.

Global Forest Watch, a WRI program, says Cambodia lost a total of 1.44 million hectares-or 14,471 square km-of forest between 2001 and 2013. That put Cambodia 23rd in the world for total forest cover lost, and ninth as a share of the forest cover the country had in 2000.

The WRI did not provide the total forest cover Cambodia lost by area in 2014. According to rights group Licadho, which analyzed the satellite data provided by the University of Maryland, Cambodia lost about 156,000 hectares of forest cover last year.

Also according to Licadho's analysis of the data, nearly a third of the forest cover Cambodia lost last year disappeared from inside protected areas. Forty-five percent of the loss occurred inside of economic land concessions (ELCs), large tracts of land the government leases to private companies for agri-business operations, mostly rubber plantations.

The government will not release a detailed list of all active ELCs that includes the size and boundaries of each. Licadho maintains a list based on the piecemeal records the government does release and its own government sources.

Given the constraints, its figure for forest loss inside ELCs as a portion of total forest loss in 2014 -44.9 percent-is probably modest, said Mathieu Pellerin, a consultant for Licadho on land issues.

"This figure would jump at least to 50 percent if we added what is, clearly, plantations going beyond [their] boundaries, and if we would have the few remaining [ELC records] we're missing," he said.

**Continued to page 23**

ការិយាល័យ មេធាវី
ថូម៉ាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំនាញប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# នៅពេលប្រេសិតសហប្រជាជាតិមកដល់អ្នកការពារសិទ្ធិមនុស្ស មានចម្ងល់ចំពោះប្រសិទ្ធភាព

**ដោយ Anthony Jensen | September 17, 2015**

នៅពេលលោកស្រី រ៉ូណា ស្មីត អ្នកធ្វើរបាយការណ៍ពិសេសថ្មីរបស់អង្គការសហប្រជាជាតិផ្នែកសិទ្ធិមនុស្សនៅកម្ពុជាបានចាប់ផ្តើមការធ្វើទស្សនកិច្ចជាផ្លូវការលើកដំបូងរបស់លោកស្រីនៅប្រទេសនេះកាលពីថ្ងៃពុធ សកម្មជនសិទ្ធិមនុស្សសំខាន់ៗយល់ឃើញផ្សេងគ្នាអំពីតួនាទីរបស់លោកស្រីដែលអាចមានឥទ្ធិពលលើស្ថានការណ៍ជាក់ស្តែង។

លោកស្រី ស្មីត សាស្ត្រាចារ្យច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅសាកលវិទ្យាល័យ ណ័រសាំប្រៀ នៃប្រទេសអង់គ្លេសទទួលបានការយល់ព្រមតែងតាំងជាប្រេសិតសិទ្ធិមនុស្សអង្គការសហប្រជាជាតិថ្មីបំផុតប្រចាំប្រទេសកម្ពុជាកាលពីខែមីនា ដោយបន្តការងារពីលោក សុរិយា ស៊ូបេឌី (Surya Subedi) ដែលបានចប់អាណត្តិ៦ឆ្នាំរបស់លោកនៅដើមឆ្នាំនេះ។

ដំណើរទស្សនកិច្ចរបស់លោកស្រី ស្មីត ដែលកាលពីដំបូងគ្រោងធ្វើនៅខែឧសភា ត្រូវបានលប់ចោល ព្រោះ "មូលហេតុភ័ស្តុភារ" ហើយត្រូវបានរៀបគម្រោងជាថ្មីសម្រាប់ខែនេះ។

យោងតាមសេចក្តីប្រកាសព័ត៌មានពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនបានឱ្យដឹងថា ការធ្វើទស្សនកិច្ចរបស់លោកស្រីដែលនឹងបញ្ចប់នៅថ្ងៃព្រហស្បតិ៍ក្រោយនេះ គ្រោងនឹងជួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមេដឹកនាំសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន។

សកម្មជនសិទ្ធិមនុស្សក្នុងស្រុកបាននិយាយកាលពីថ្ងៃពុធថា ពួកគេមានផែនការជម្រាបលោកស្រី ស្មីត យ៉ាងសង្ខេបអំពីបញ្ហាជាច្រើនដែលកំពុងប្រឈមនឹងប្រទេសនេះ ប៉ុន្តែបានផ្តល់មតិចម្រុះអំពីថា តើមានឥទ្ធិពលប៉ុន្មានដែលលោកស្រីអាចមានលើសកម្មភាពរបស់រដ្ឋាភិបាល។

លោក សួន ប៊ុនសក្តិ លេខាធិការប្រតិបត្តិនៃគណៈកម្មាធិការប្រព្រឹត្តិកម្មនៃសមាគមការពារសិទ្ធិមនុស្សកម្ពុជាបាននិយាយថា លោកមានផែនការលើកប្រធានបទបីដោយឡែកពីគ្នា គឺបញ្ហាដីធ្លីតុលាការ និងកំណែទម្រង់ការបោះឆ្នោតក្នុងជំនួបជាមួយលោកស្រី ស្មីត នៅថ្ងៃនេះ។

លោក ប៊ុនសក្តិ បាននិយាយថា លោកជឿថា អ្នកធ្វើរបាយការណ៍ពិសេសរូបនេះមានតួនាទីសំខាន់ក្នុងការរំឭករដ្ឋាភិបាលនូវការប្តេជ្ញាជាអន្តរជាតិរបស់ខ្លួនក្នុងការការពារសិទ្ធិមនុស្ស។

លោក ប៊ុនសក្តិ បាននិយាយថា "យើងត្រូវការជំនាញការថ្នាក់ខ្ពស់បែបនេះ គឺក្រុមមន្ត្រីអង្គការសហប្រជាជាតិដើម្បីឃ្លាំមើលស្ថានការណ៍សិទ្ធិមនុស្សក្នុងប្រទេស"។

លោកបានបន្តទៀតថា អ្នកធ្វើរបាយការណ៍ពិសេសចាំបាច់ត្រូវ "ណែនាំរដ្ឋាភិបាលឱ្យនិង" ឱ្យពួកគេទទួលខុសត្រូវចំពោះសកម្មភាព ចំពោះដំណោះស្រាយចំពោះការធ្វើឱ្យប្រសើរឡើង"។

លោក នី ចរិយា ប្រធានផ្នែកស៊ើបអង្កេតសមាគមអាដហុកដែលខ្លួនលោកផ្ទាល់បានប្រឈមនឹងការគំរាមកំហែងខាងផ្លូវច្បាប់ដោយសារតែការងារតស៊ូមតិរបស់លោកក្នុងពេលប៉ុន្មានខែថ្មីៗកន្លងមកនេះ បាននិយាយថា អង្គការរបស់លោកនឹងរាយការណ៍ទៅលោកស្រី ស្មីត អំពី "សន្តិសុខសម្រាប់អ្នកការពារសិទ្ធិមនុស្ស... សេរីភាពនៃការបញ្ចេញមតិ និងលម្ហសម្រាប់សកម្មភាពនយោបាយ"។

ដោយលើកឡើងពីការចាប់ខ្លួននាពេលថ្មីៗនេះនៃយុវជនពីរនាក់ ឈ្មោះ គង់ រ៉ាយ៉ា និង ផង់ សីហា ដោយសារការបង្ហោះលើបណ្តាញព័ត៌មានសង្គមលោក ចរិយា បាននិយាយថា "ខ្ញុំគិតថា

**តទៅទំព័រទី ២៣**

# As UN Envoy Arrives, Rights Defenders Question Sway

BY ANTHONY JENSEN | SEPTEMBER 17, 2015

As Rhona Smith, the U.N.'s new special rapporteur on human rights in Cambodia, began her first official visit to the country Wednesday, leading human rights activists were at odds over how much her position could influence the situation on the ground.



Ms. Smith, a professor of international human rights law at Northumbria University in the U.K., was approved as the latest U.N. human rights envoy to the country in March, succeeding Surya Subedi, whose six-year mandate ended earlier this year.

A trip by Ms. Smith originally planned for May was canceled for "logistical reasons" and rescheduled for this month.

Her visit, which will end next Thursday, is set to include meetings with Prime Minister Hun Sen, Interior Minister SarKheng, civil society leaders and local communities, according to a statement from the Office of the U.N. High Commissioner for Human Rights.

Local rights activists said Wednesday that they planned to brief Ms. Smith on a litany of problems facing the country, but offered mixed opinions on how much of an impact, if any, she could have on the government's actions.

SuonBunsak, executive secretary of the Cambodian Human Rights Action Committee, said he planned to address three separate topics-land issues, the judiciary and electoral reform-in a meeting with Ms. Smith today.

Mr. Bunsak said he believed the special rapporteur had a significant role to play in reminding the government of its international commitments to protect human rights.

"We need such high-ranking expertise -U.N. officials to keep watching the situation of human rights in the country," Mr. Bunsak said.

The special rapporteur, he said, was necessary "to advise the government [and] to hold them accountable for actions, for resolutions, for improvement."

NyChakrya, head of monitoring for rights group Adhoc, who has himself faced legal threats for his advocacy work in recent months, said that his organization would report to Ms. Smith on "security for human rights defenders…freedom of expression and space for political activities."

"I think the situation is worse than before if you compare with the space for expression in the past," Mr. Chakrya said, citing the recent arrests of two young men-Kong Raya and PhongSeiha-for posts on social media.

Mr. Raya called for a "color revolution" on his personal Facebook page while Mr. Seiha took to the website to threaten the life of Sok Touch, a prominent academic who has been tasked by the government with studying the demarcation of the border with Vietnam.

Mr. Chakrya added that the failure on the part of authorities to investigate the fatal police shootings of five protesters in January last year and the recent conviction of 11 opposition activists on what are widely believed to be spurious insurrection charges was evidence that the human rights situa

**Continued to Page 16**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# តារាសម្តែងហូលីវូដ អ៊ែនជែលីណា ចូលី ជួបពិភាក្សាជាមួយលោក ហ៊ុន សែន

**ដោយឃី សុវុឌ្ឍី** | September 18, 2015

អ្នកនាំពាក្យលោកនាយករដ្ឋមន្ត្រីបានឱ្យដឹងថា អ្នកនាង អ៊ែនជែលីណា ចូលី បានជួបពិភាក្សាជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅវិមានសន្តិភាពកាលពីម្សិលមិញដើម្បីពិភាក្សាអំពីខ្សែភាពយន្តមានចំណងជើងថា "ពីដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ" ដែលអ្នកនាងនឹងចាប់ផ្តើមថតក្នុងពេលឆាប់ៗ និងតំបន់អភិរក្សមួយកន្លែងក្នុងខេត្តបាត់ដំបងដែលការពារដោយតារាសម្តែងដ៏ល្បីល្បាញរូបនេះ។

តារាហូលីវូដដ៏ល្បីឈ្មោះរូបនេះ ដែលបានសុំកូនឈ្មោះម៉ាដុក (Maddox) ពីមណ្ឌលកុមារកំព្រាកម្ពុជាយកទៅចិញ្ចឹមកាលពីឆ្នាំ២០០២ បានប្រកាសនៅក្នុងខែកក្កដាថា អ្នកនាងនឹងដឹកនាំផលិតខ្សែភាពយន្តនេះដោយផ្អែកលើការចងចាំដែលសរសេររៀបរាប់ដោយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ឈ្មោះ លឿង អ៊ុង ។

អ្នកនាង អ៊ែនជែលីណា ចូលី បានពិភាក្សាអំពីគម្រោងនេះជាមួយលោកនាយករដ្ឋមន្ត្រី ហើយបានសង្កត់ធ្ងន់ថា គោលបំណងនៃការផលិតខ្សែភាពយន្តនេះគឺដើម្បីអប់រំនិងបង្ហាញទស្សនិកជនឱ្យស្គាល់ពីវប្បធម៌ខ្មែរជាជាងផ្តោតលើអំពើដ៏ព្រៃផ្សៃនៅក្នុងរបបខ្មែរក្រហម នេះបើយោងតាមលោក អៀង សុផាឡែត ជំនួយការផ្ទាល់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។

លោកបានថ្លែងថា "ខ្សែភាពយន្តនេះផ្អែកលើសៀវភៅមួយក្បាលដែលឆ្លុះបញ្ចាំងអំពីជីវិតរបស់ក្មេងស្រីគ្រប់រូបរស់នៅក្នុងភ្លើងសង្គ្រាម។ នេះមិនមែនជារឿងដែលឆ្លុះបញ្ចាំង តែពីអំពើដ៏ព្រៃផ្សៃទេ ប៉ុន្តែ វាក៏ឆ្លុះបញ្ចាំងអំពីប្រជាពលរដ្ឋ វប្បធម៌ ទំនៀមទម្លាប់ និងក្រុមគ្រួសារនៅក្នុងសង្គមខ្មែរផងដែរ។ ជាពិសេសវានឹងបង្ហាញអំពីសេចក្តីស្រឡាញ់របស់ឪពុកម្តាយដែលមានចំពោះកូនៗរបស់ខ្លួន"។

លោក អៀង សុផាឡែត បានលើកឡើងទៀតថា លោកនាយករដ្ឋមន្ត្រី និងតារាសម្តែងដ៏ល្បីឈ្មោះរូបនេះក៏បានពិភាក្សាគ្នាអំពីស្ថានភាពនៃតំបន់ការពារនៅក្នុងស្រុកសំឡូត ខេត្តបាត់ដំបង ជាកន្លែងដែលលោក ហ៊ុន សែន បានលុបចោលគម្រោងសាងសង់ទំនប់វារីអគ្គិសនីមួយ បន្ទាប់ពីអ្នកឈ្នះពានរង្វាន់អូស្ការូបនេះបានបញ្ចុះបញ្ចូលឱ្យមានការលុបចោលកាលពីឆ្នាំ២០០៤ផងដែរ។ ទំនប់វារីអគ្គិសនីនេះ ដែលគេគ្រោងសាងសង់ឆ្លងកាត់ទន្លេក្នុងស្រុកសំឡូតនឹងធ្វើឱ្យលិចលង់ភូមិមួយក្នុងមូលដ្ឋាន។



Angelina Jolie-Pitt and Prime Minister Hun Sen speak at Mr Hun Sen's office building in Phnom Penh on Thursday. (PringSamrang/Reuters)

លោកបានមានប្រសាសន៍ថា "អ្នកនាងបានប្រាប់សម្តេចឱ្យ ហ៊ុន សែន" ថា តំបន់ការពារសំឡូតកំពុងតែអភិវឌ្ឍបានយ៉ាងល្អប្រសើរ។ ប្រសិនបើយើងមើលពីលើអាកាសមកយើងឃើញព្រៃឈើដ៏ខៀវស្រងាត់ ហើយពួកគាត់ឱ្យលោក ហ៊ុន សែន និងអ្នកនាង អ៊ែនជែ លីណា ចូលី "កំពុងតែរួមដៃគ្នាដើម្បីការពារធនធានព្រៃឈើនៅកម្ពុជា"។

ខ្សែភាពយន្តដែលនឹងផលិតក្នុងពេលឆាប់ៗនេះ នឹងត្រូវបញ្ចេញដើម្បីចាក់បញ្ចាំងដោយក្រុមហ៊ុនអនឡាញ Netflix ហើយគេគ្រោងនឹងចាប់ផ្តើមផលិតនៅចុងឆ្នាំនេះ រីឯថ្ងៃចាក់បញ្ចាំងគឺនៅឆ្នាំ២០១៦។ ហើយវានឹងមានការសហការផលិតដោយផលិតករភាពយន្តខ្មែរមួយរូបឈ្មោះ ប៉ាន់ ឫទ្ធី។

អ្នកផ្តល់ព័ត៌មានសម្រាប់អ្នកនាង អ៊ែនជែលីណា ចូលី មិនអាចទាក់ទងសុំការធ្វើអត្ថាធិប្បាយបានឡើយ ៕ **ស៊ុយ ឈា**

## Angelina Jolie-Pitt, Hun Sen Meet to Discuss Film

**BY KHY SOVUTHY | SEPTEMBER 18, 2015**

Angelina Jolie-Pitt met with Prime Minister Hun Sen at the Peace Palace on Thursday to discuss her upcoming movie "First They Killed My Father" and a conservation area in Battambang championed by the actress, a spokesman for the prime minister said.

The Hollywood superstar, who adopted her son Maddox from a Cambodian orphanage in 2002, announced in July that she would direct an adaptation of the memoir penned by Khmer Rouge survivor Loung Ung.

Ms. Jolie-Pitt discussed the project with the prime minister and emphasized that the aim of the film is to educate the audience on Cambodian culture rather than focus on the brutality of the Khmer Rouge, said EangSophalleth, a personal assistant of Prime Minister Hun Sen.

"The film is based on a book that reflects the life of every female child during the war. This is a film that not only reflects the cruelty, but will also reflect the people, culture, customs, and family groups in Cambodia," Mr. Sophalleth said. "Especially it will show the love of parents for their children."

Mr. Sophalleth said the pair also discussed the state of a protected area in Battambang province's Samlot district where plans for a hydropower dam were scrapped by Mr. Hun Sen after Ms. Jolie-Pitt lobbied against them in 2004. The dam, which was scheduled to be built on the Samlot River, would have flooded a local village.

"She told Samdech [Hun Sen] that the Samlot protection area is developing well," he said. "If we look from above you can see the green forest, and they [Mr. Hun Sen and Ms. Jolie-Pitt] are joining to protect forestry resources in Cambodia."

The upcoming film will be released by online streaming company Netflix, and shooting is scheduled to commence later this year, with a release date in 2016. It will be co-produced by Cambodian filmmaker RithyPanh.

Ms. Jolie-Pitt's press officer could not be reached for comment.

sovuthy@cambodiadaily.com

**Continued from page 15**

## As UN Envoy Arrives, Rights...

tion in the country was on the decline.

"This is clear evidence that the situation for political activists in the country is very dangerous," he said.

Still, he said he doubted Ms. Smith's ability to hold the government to account.

"Based on my experience, the government doesn't accept the special rapporteur as an adviser," he said. "They see the special rapporteur as the opposition. That is the problem."

OuVirak, a political analyst and founder of the Future Forum think tank, agreed that the special rapporteur held little clout in the country.

"The significance of that role is actually on the decline every single year," Mr. Virak said, noting that increasing support from China was steadily diminishing the U.N.'s leverage in Cambodia.

"That's unfortunately how the world works and there's very little the U.N. can do about or is willing to do about it," he said.

"I think she's going to have an uphill battle," he said of Ms. Smith. "Her mandate is still there, although I think the commitment no longer is."

**(Additional reporting by Kuch Naren)**

ឌី ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌី ខេមបូឌា ដេលី

# ក្រុមប្រឆាំងដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិកនឹងតវ៉ា ប្រឆាំងលោក ហ៊ុន សែន នៅក្នុងទីក្រុងញូវយ៉ក

**ដោយអេឡិក វិល្លីមមីនស៍ និងគុច ណារ៉េន** | September 23, 2015

មេដឹកនាំក្រុមប្រឆាំងមួយមានមូលដ្ឋាននៅសហរដ្ឋអាមេរិកដែលជួយផ្តល់ហិរញ្ញវត្ថុដល់យុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិកាលពីឆ្នាំ២០១៣ បានលើកឡើងកាលពីម្សិលមិញថា នឹងមានការតវ៉ាប្រឆាំងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អំឡុងដំណើរនាចុងសប្តាហ៍របស់លោកទៅកាន់អង្គការសហ-ប្រជាជាតិនៅក្នុងទីក្រុងញូវយ៉កដោយធ្វើឱ្យមានការកម្រើកឡើងវិញនូវការតវ៉ារបស់គណបក្សប្រឆាំងដែលស្រែកថា "ហ៊ុន សែន អើយ ចុះចេញទៅ"។

លោក ហ៊ុន សែន គ្រោងថ្លែងនៅក្នុងកិច្ចប្រជុំកំពូលអង្គការសហប្រជាជាតិនៅថ្ងៃសៅរ៍ ហើយលោក ទូច វិបុល ប្រធានមូលនិធិសង្គ្រោះជាតិខ្មែរបានលើកឡើងថា លោកនឹងរៀបចំការតវ៉ានៅខាងក្រៅទីស្នាក់ការអង្គការសហប្រជាជាតិ ដើម្បីអំពាវនាវឱ្យអង្គការនេះធ្វើអន្តរាគមន៍នៅកម្ពុជា។

លោកបានមានប្រសាសន៍ថា "យើងចង់ឱ្យអង្គការសហប្រជាជាតិចាប់ផ្តើមស៊ើបអង្កេតលើបទល្មើសរំលោភបំពានសិទ្ធិមនុស្សដោយគណបក្សកាន់អំណាចនៅកម្ពុជា។ មានការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនៅកម្ពុជា ហើយពលរដ្ឋគ្រប់រូបសុទ្ធតែដឹងរឿងនេះ"។

លោកបានបន្ថែមថា "យើងក៏ចង់ឱ្យអង្គការសហប្រជាជាតិឃ្លាំមើលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨ ផងដែរដើម្បីធ្វើឱ្យប្រាកដថាវាសេរី និងយុត្តិធម៌។ លោក ហ៊ុន សែន បានលើកឡើងម្តងហើយម្តងទៀតថា នឹងមានសង្គ្រាមប្រសិនបើលោកចាញ់ការបោះឆ្នោត ហេតុដូច្នេះយើងទទូចសុំឱ្យអង្គការសហប្រជាជាតិធានានូវការផ្ទេរអំណាចដោយសន្តិវិធីបន្ទាប់ពីការបោះឆ្នោត"។

ប៉ុន្តែលោកបានសង្កត់ធ្ងន់ថា មូលនិធិសង្គ្រោះជាតិខ្មែរគ្មានទំនាក់ទំនងជាមួយគណបក្សសង្គ្រោះជាតិឡើយ ទោះបីជាមានឈ្មោះស្រដៀងគ្នា និងទោះបីជាអង្គការរបស់លោកបានធ្វើឱ្យមានការកម្រើកឡើងវិញនូវការតវ៉ាស្រែកថា "ហ៊ុន សែន អើយ ចុះចេញទៅ" ដែលជាពាក្យពេញនិយមអំឡុងការតវ៉ារបស់គណបក្សសង្គ្រោះជាតិកាលពីឆ្នាំ២០១៣ក៏ដោយ។

លោក ទូច វិបុល បានមានប្រសាសន៍បន្ថែមទៀតថា "នៅក្នុងឆ្នាំ២០១២ និងឆ្នាំ២០១៣ យើងបានរៃអង្គាសមូលនិធិដើម្បីជួយគាំទ្រលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ងាកត្រឡប់ទៅអំឡុងពេលនោះវិញ វាគឺជាចលនាគាំទ្រលោក កឹម សុខា និង លោក សម រង្ស៊ី ឱ្យមេដឹកនាំគណបក្សសង្គ្រោះជាតិ "ដើម្បីគាំទ្រលទ្ធិប្រជា-ធិបតេយ្យ។ ការតវ៉ានេះមិនមែនរៀបចំឡើងដោយពួកគាត់ទេ"។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានលើកឡើងថា វាមិនមែនជាលើកទី១ទេដែលអាណិកជនខ្មែររស់នៅសហរដ្ឋអាមេរិកបានតវ៉ាប្រឆាំងលោក ហ៊ុន សែន

**តទៅទំព័រទី២១**



រូបថតវិបុល ទូច

# US-Based Opposition Group to Protest Hun Sen in New York

BY ALEX WILLEMYNS AND KUCH NAREN | SEPTEMBER 23, 2015

The leader of a U.S.-based group that helped finance the Cambodia National Rescue Party's 2013 election campaign said Tuesday that it would protest against Prime Minister Hun Sen during his weekend trip to the U.N. in New York by rekindling the opposition party's "Hun Sen Must Go " protests.

Mr. Hun Sen is scheduled to speak at a U.N. summit on Saturday, and Touch Vibol, the president of the Cambodia National Rescue Foundation, said he organized the rally outside U.N. headquarters to call for it to intervene in Cambodia.

"We want the U.N. to initiate investigations into the alleged human rights crimes committed by the Cambodian ruling party. There are serious abuses of human rights in Cambodia, and everyone knows that," Mr. Vibol said.

"We also want the U.N. to monitor the 2018 election to make sure they are free and fair. Hun Sen has repeatedly said there will be war if he loses the election, so we urge the U.N. to ensure a peaceful transition of power after the election."

Yet Mr. Vibol stressed that the Cambodia National Rescue Foundation had no organizational links to the CNRP, despite the similarity of their names and the group's recycling of the "Hun Sen Must Go" slogan that dominated the CNRP's 2013 protests.

"In 2012 and 2013, we raised funds to help democracy in Cambodia. Back then, it was a movement to support [CNRP leaders] KemSokha and Sam Rainsy to support democracy. This protest is not organized by them," Mr. Vibol said.

CPP spokesman SokEysan said it was not the first time Cambodian-Americans had protested against Mr. Hun Sen during one of his trips to the U.N., and that the turnout for such events tended to be low.

"They are formerly from the Khmer Republic of Lon Nol, so they have maintained their anger against the CPP," Mr. Eysan said. "It is nothing strange, since brothers and sisters abroad do not know about Cambodia's present internal situation well."

Mr. Vibol denied that his group was made up of ex-Lon Nol officials.

"It's not true. We are just Cambodian-Americans. Most of us are the younger generation and we are coming out to express our concerns about human rights in Cambodia," he said.

Opposition leader Sam Rainsy said that even if the Cambodia National Rescue Foundation had provided money to the CNRP in the 2013 election, it no longer funded the party. He said if the organization held an anti-Hun Sen rally it would have no impact on his present rapprochement with the premier.

"The Cambodian National Rescue Foundation is totally different to the Cambodian National Rescue Party. There has been confusion in the past," Mr. Rainsy said. "The CNRP does not get money from that organization. We have no links.

"They live in a democratic country, in the U.S., so they can do whatever they want within U.S. law. Some of them are CNRP supporters, but we have countless supporters and cannot dictate things to them, especially when they are abroad."

# វាសនា នួន បេក្ខជនក្រុមប្រឹក្សាក្រុងឡូវែល
# VESNA NUON FOR CITY COUNCIL

លោក វាសនា នួន បានបើកយុទ្ធនាការឃោសនា នាថ្ងៃទី១៥កញ្ញា ២០១៥ នៅភោជនីយដ្ឋាន គ្គាស្យា-ប្រូគ្គន សម្រាប់ថ្ងៃបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាក្រុង នាទីក្រុង-ឡូវែលទី២៩កញ្ញា សម្រាប់តួនាទី ក្រុមប្រឹក្សាក្រុងឡូវែល ។ ភ្ញៀវប្រមានជា៦០នាក់ នឹងលោកស្រីព្រឹទ្ធសមាជិកសភាអាមេរីកាំង នីគី ស៊ុងគ្គាស បានអញ្ជើញមកគាំទ្របេក្ខភាព ហើយបាននិយាយថា "លោកស្រីចង់ឃើញលោក វាសនា នួន ត្រឡប់មកកាន់ក្រុមប្រឹក្សាក្រុងឡូវែលវិញ ហើយមិនមានការសង្ស័យទេថា លោកនឹងបំរើក្រុងឡូវែលដ៏ល្អនេះជាថ្មីម្តងទៀត រឹតតែប្រសើជាងមុនទៅទៀត ។

សូមអានសេចក្តីរាយការណ៍ ប៉ុន ណូខាំ ជាភាសាអង់គ្លេសដូចតទៅនេះ:

**By Pon Nokham**

(Lowell, MA) Attending a fundraiser for Lowell City Council candidate Vesna Nuon, Congresswoman Niki Tsongas complimented Nuon for his previous community service and said she would look forward to working with him on a return to the Lowell City Council, stating, "I have no doubt that he will serve this great city again with great distinction. "Tsongas, at a Nuon fundraiser at Garcia-Brogan's restaurant with some sixty people in attendance, added, "Vesna will bring true passion and commitment to public education and to making our city safe."



លោក វាសនា នួន និង [illegible] ក្លាស ព្រឹទ្ធសមាជិក

Further, Tsongas cited Nuon's strong ability "to reach out to people." She also credited him with being able to work with diverse groups of people towards positive results. "He will work with people to get to yes," stated Tsongas.

Nuon thanked Congresswoman Tsongas for her support. "I am very grateful for Congresswoman Tsongas' positive words and confidence in my abilities. For a number of years I've had the privilege of working with Niki Tsongas on youth issues as well as on education and public safety initiatives. She is an extremely dedicated public servant and someone who is a great role model and genuine community leader."

"My campaign theme for Lowell City Council is stronger together," said Nuon. Being able to have public officials with different experiences and backgrounds working together – this is an advantage that will help tackle and solve critical issues facing ourcity. Once again, I am thankful to Niki for voicing confidence in me in this effort to contribute to our community as a Lowell City Councilor."

For additional information, Pon Nokham, nokhamlaw@live.com


សាលាថែទាំកុមារឡូវែល

LOWELL DAY NURSERY ASSOCIATION

119 HALL STREET
LOWELL, MASS.01854
978-454-5981

- កំពុងបើកទទួលសិស្សានុសិស្សកុមារអាយុ១៥ខែ រហូតដល់២ឆ្នាំ៩ខែ
- សាលាមុនថ្នាក់មតេយ្យ
- មានបុគ្គលិកប្រកបគរុកោសល្យល្អ
- ជាសាលាល្អចំណាត់ថ្នាក់ប្រចាំឆ្នាំ

- OPENINGS AVAILABLE! TODDLERS -15 MONTHS THRU 2YEARS 9 MONTHS
- PRESCHOOL AND KINDERGARTEN
- GREAT CURRICULUM WITH SEASONED STAFF
- NATIONAL DIRECTOR OF THE YEAR

www.lowelldaynursery.com
or Like us on Facebook – Lowell Day Nursery Association






## វិធីសាស្ត្រព្យាបាលជំងឺឬសដូងបាតធានាជា ១00%

វិធីធ្វើគឺងាយស្រួលទេមាន២យ៉ាង១មើមឆៃថាវ ២ទឹកឃ្មុំសុទ្ធរបៀបធ្វើជាដំបូងយកមើមឆៃថាវសុទ្ធ១ឬ២មើមមកលាងទឹកអោយស្អាតរួចកាត់ក្បាលស្លែចោលបុកអោយម៉ត់ច្របាច់យកទឹក១ស្លាបព្រាខ្លីលាយជាមួយទឹកឃ្មុំ១ស្លាបព្រាដូចគ្នាកូរអោយចូលគ្នារួចហើយហូបមុន និងចូលដេក( សូមកុំហូបទឹកតាមក្រោយតែបើរចង់ហូបតែមួយក្អឹកបានហើយ) អ្នកដែលទើមតែកើតអោយហូប១ថ្ងៃ៣ដង អ្នកដែលកើតយូហើយអោយហូប១ថ្ងៃតែ១ដងទេតែហូបរាល់ថ្ងៃរយ:ពេល១៥ថ្ងៃទៅ១ខែមុននិងចូលដេក ចំពោះអ្នកដែលកើតជំងឺរីសដូងបាតតូទ ។





# វិធីព្យាបាលដោយកាយវប្បកម្មនៅមេរីម៉ែក-វ៉ាលី, និងនៅ វូបឿន

## Merrimack Valley Physical Therapy And

## Physical Therapy of Woburn

**Mission Statement:** សេចក្តីថ្លែងការអំពីគោលបំណង

ផ្តល់គុណភាពក្នុងការថែរក្សាសុខភាព, ធ្វើឲ្យមានសុខភាពប្រសើរឡើង និង ដំណើរជីវិតឲ្យមានភាពសកម្មជាងមុន, យើងមានជើថាការជំជួយដល់មនុស្សឲ្យ មានរាងកាយនិងស្មារតីមាំមួនតាមរយៈការព្យាបាលធ្វើលំហាត់ប្រាណ,និងជួយ ដល់អ្នកជម្ងឺបានជាសះស្បើយឡើងវិញបាន.

To provide quality health care in order to promote healthier and more active lifestyles. We believe in helping people strengthen their bodies and minds through therapeutic exercise and helping people recover from injuries.

- Back Issue Program :ការបញ្ហាញកម្មវិធីផ្នែកខាងក្រោយ
- Pre-natal Program :កម្មវិធីមុនកំណើតកូន
- Pre and Post-Operative Care :ថែទាំមុននិងក្រោយពេលព្យាបាលជម្ងឺ
- Injuries dues to auto accident :របួសមកពីគ្រោះថ្នាក់ពីរថយន្ត
- Worker's Compensation Claims :ទាមទារសំណងសម្រាប់អ្នកពលកម្ម
- Slips and Falls :រំអិលដួល
- Sport Injuries :របួសកីឡា
- Translations in Khmer and Vietnamese now available:មានការបកប្រែជាភាសាខ្មែរនិងវៀត-ណាម

**សូមទាក់ទងនិង:សេរីណា វ៉ាន-យ៉ាញ, ទូរស័ព្ទលេខ:៩៧៨-៥៦៩-៣១២០,Contact Serina Van-Danh at 978-569-3120,**

**ការណាត់ជួបជាមួយយើងខ្ញុំតាមរយៈអាសយដ្ឋាន២កន្លែងខាងក្រោម៖**

**To schedule an appointment, please contact us at one of our 2 locations:**

Lawrence :
225 Essex St. Unit 1E
Lawrence, MA 01840
Tel: 978-208-0402/978-258-2908

Woburn :
400 West Cummings Park, Suite 1400
Woburn, MA 01801
Tel: 781-938-1223

# ទៅកម្សាន្តនឹងទេសភាព ទឹកជ្រោះជួរភ្នំជុំជិតព្រឹក្សព្រៃ "ថ្មរូង"







ហាស់! ហាំ... គយគន់ទឹកជ្រោះឈ្មោះនឹងថ្មដា ស្តាប់សៀងវាំគា ថ្ងូចថ្ងូរខ្ទរព្រឹក្សព្រៃផ្អើលអស់បក្សីស្រដីខ្សៀវខ្សាររុក្ខាមានភ័ព្វជាប់ជួរអន្លាយលើភ្នំឆើតឆាយស្រស់ស្រាយខៀវខ្ចី.មាត់អូរហូរទឹកសទឹករោងស្បូវ មនុស្សម្នារញ៉ូវទៅលេងផ្កាត្រែង ហាក់គ្មានចំបែងប្រឡែងគ្នាស្និទ្ធ ទេសភាពល្អពិត ដ្បិតមានប្រុស-ស្រី. ហក្កាក្បង់ទឹកទឹកដល់កញ្ចាមុជលេងជលសាគាប់នេត្រាក្រៃមិត្តយើងឯណេះចេះចាំចរណៃកុំយូរពេកថ្លៃលែលកអាហារ...។ ទេសភាពបែបនេះ នៅឯណាមាន? គឺនៅរមណីយដ្ឋាន "ថ្មរូង"។ សូមជំរាបថា រមណីយដ្ឋាន "ថ្មរូង" ពិតជាមានទេសភាពស្រស់ត្រកាលដូចពាក្យកាព្យរៀបរាប់លើអញ្ចឹង... ប្រសិនបើយើងធ្វើដំណើរទៅកម្សាន្តទីនោះនារដូវប្រាំងទេសភាពហាក់ក្រៀមក្រោះបន្តិចព្រោះតែទឹកហូរតិចតួច ឯដើមឈើធំ-តូចខ្លះស្លោកស្លឹកស្រពាប់ផ្ទាំងថ្មចង្រ្កឹងនៅធ្មឹងស្ងួតទឹកគ្មានសំឡេងរអឹកឈ្ងូឆរអ្វីឡើយ ។ ប្រសិនបើទៅលេងនារដូវវស្សាវិញ ធានាថា គ្មានទុក្ខទោមនេញនឹងបរិយាកាសទាំងឡាយនោះឡើយ ដោយសារតែធម្មជាតិស្រស់ខៀវខ្ចីមានភ្នំព្រឹក្សព្រៃព័ទ្ធជុំវិញទឹកជ្រោះ ទឹកអូហូរខ្លាំងៗ បែកផ្កាត្រែងបង្អសំឡេងឈ្ងូឆរគ្មានដាច់ខ្យល់បក់រំៗដើមរុក្ខារេរាំនាំក្លិនពិដោររប៉ះផាត់រាងកាយប្រុស-ស្រីសត្វស្លាបហិចហើរបង្ហើរវាំចាញ្ចសូរខ្សៀវខ្សារគួរមេត្រីមនុស្សម្នាអ៊ូអរស្លូចិត្តកម្សាន្ត រួចហើយប្រះប្រាណគេងលើអង្រឹង ។

ទីនេះមានលក់ម្ហូបអាហាររាប់សិបមុខត្រីដុត មានដុត សម្លម្ជូរ កកូរ ឆាអាំង ជ្រូក គោមាន់ ទា ម្ហូបម្នាតាមចិត្ត ជាពិសេសសាច់សត្វព្រៃលែលកកុម្ម៉ង់ ឆីមានឱជារស។ មានរោងស្បូវនិងក្បូសមិនខុសចិន្តាជួលញ៉ាំអាហារមិនថ្លៃពេកទេ ទម្រេតខ្លួនប្រាណបានលើអង្រឹងធ្វើហាក់មិនដឹងមិនមានរឿងអ្វី ។ ចង់មុជទឹកលេងប្រឡែងធម្មជាតិក៏បានមានស្រស់កល្យាណនៅក្បែរៗយើង... ស្រង់ទឹករួចរៀបចំខ្លួនសូរិយាអង្រួនជូនដល់សាយ័ណ្ហ ត្រាន់ត្រៃវិលវិញ ។ គួរបញ្ជាក់ថាទៅកាន់រមណីយដ្ឋានថ្មរូងធ្វើដំណើរតាមផ្លូវជាតិលេខ៤រយៈចម្ងាយ១១៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ...ទៅហួសជ្រោះជ្រងពេជ្រនិលបន្តិចឃើញមានដាក់ស្លាកខាងស្តាំដៃ "រមណីយដ្ឋានថ្មរូង" បត់ចូលតាមផ្លូវក្រាលក្រួសក្រហមបត់បែនឡើងចុះតាមជើងភ្នំ ប៉ុន្តែមិនពិបាកទេ ប្រហែល៥គីឡូម៉ែត្រនឹងដល់រមណីយដ្ឋានហើយ ស្ថិតក្នុងស្រុកកំពង់សិលា ខេត្តព្រះសីហនុ ជាប់ព្រំប្រទល់ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ៕





## AMERICAN MUFFLER & BRAKE



យានដ្ឋានខ្មែរជួសជុលរថយន្តធូរទៅតម្លៃសមរម្យ

Known as A muffler man. Customize pipe, exhaust & welding. come to see us we can make the different.

Shock & Struts, Tune-up, Axle Trans, Timing Belt, Customized Pipe Exhaust Clutch, Water Pump, Starter and much more...

WE FIX-U $SAVE

1380 Park Ave.
Cranston, RI 02920
Cell: 203-522-2174
www. amufflerman.com

Monday-Saturday 8:00 am-7:00 pm
Open Sunday 9:00 am-3:00 pm
Phone: 401-944-3390 Fax: 401-944-3390

**Mony, Chay, Sokheang, Sokheng & Jimmy**

WE ARE AT FIVE LOCATIONS

| | | | |
|---|---|---|---|
| 1412 Park Ave. | 335 Whalley Ave. | 1355 South Main St. | 219N. Colony Rd. |
| Bridgeport, CT 06604 | New Haven, CT 06511 | Waterbury, CT 06706 | Wallingford, CT 06492 |
| (203) 333- 0355 | (203) 777- 9800 | (203) 757-7575 | (203) 284-0861 |



## រកអ្នកធ្វើការ -ជាងធ្វើក្រចកស្រី ឬបុរស

ប្រាក់ខែជូនទៅតាមបទពិសោធន៍ពី $៥០០-$១.០០០ ក្នុង១អាទិត្យ

កន្លែងធ្វើការរវល់ច្រើន

Trenton, NJ ចម្ងាយ៤៥នាទី ពីហ្វីឡាដែលហ្វៀ

សម្រាប់អ្នកនៅឆ្ងាយមានកន្លែងឱ្យសំណាក់

ទូរស័ព្ទ : **609-227 1939**

## Help wanted – Nail Technician M or F

Salary base on experience $500-$1,000/week

Busy location, Trenton, NJ 45mn.from Philly

For long distance, Provided accommodation

Call **609-227 1939**


## តមកពីទំព័រទី ១៧ ក្រុមប្រឆាំងដែលមានមូលដ្ឋាននៅ...

អំឡុងដំណើរបំពេញការងាររបស់លោកទៅកាន់អង្គការសហប្រជាជាតិ ហើយថា ការចេញមកតវ៉ាបែបនេះមានទ្រង់ទ្រាយតូចតាចប៉ុណ្ណោះ។

លោកបានមានប្រសាសន៍ថា "ពួកគាត់ជាក្រុមចេញពីអតីតសាធារណរដ្ឋខ្មែរដឹកនាំដោយ លន់ នល់ ហេតុដូច្នេះពួកគាត់នៅមានកំហឹងចំពោះគណបក្សប្រជាជនកម្ពុជា។ វាគ្មានអ្វីចម្លែកទេ ព្រោះថា បងប្អូននៅក្រៅប្រទេសមិនដឹងច្បាស់អំពីស្ថានភាពផ្ទៃក្នុងនៅកម្ពុជាក្នុងពេលបច្ចុប្បន្នឡើយ"។

លោក ទូច វិបុល បានបដិសេធការដែលថា ក្រុមរបស់លោកមានសមាសភាពចេញពីអតីតមន្ត្រីសម័យ លន់ នល់ ។

លោកបានមានប្រសាសន៍ថា "វាមិនពិតទេ។ យើងគ្រាន់តែជាអាណិកជនខ្មែររស់នៅសហរដ្ឋអាមេរិកប៉ុណ្ណោះ។ ពួកយើងភាគច្រើន គឺជាក្មេងជំនាន់ក្រោយ ហើយយើងចេញមកនេះដើម្បីសំដែងក្តីព្រួយបារម្ភរបស់យើងអំពីសិទ្ធិមនុស្សនៅកម្ពុជា"។

លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងបានលើកឡើងថា ទោះបីជាមូលនិធិសង្គ្រោះជាតិខ្មែរធ្លាប់បានផ្តល់ហិរញ្ញវត្ថុឱ្យគណបក្សសង្គ្រោះជាតិ អំឡុងការបោះឆ្នោតកាលពីឆ្នាំ២០១៣ក្តី តែមូលនិធិនេះលែងផ្តល់ហិរញ្ញវត្ថុឱ្យបក្សរបស់លោកទៀតហើយ។ លោកបានលើកឡើងទៀតថា ប្រសិនបើអង្គការនេះធ្វើការតវ៉ាប្រឆាំងលោក ហ៊ុន សែន វានឹងមិនធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងល្អកល្អិនក្នុងពេលថ្មីៗរបស់លោកជាមួយលោកនាយករដ្ឋមន្ត្រីឡើយ។ លោកបានមានប្រសាសន៍ថា "មូលនិធិសង្គ្រោះជាតិខ្មែរ គឺខុសគ្នាដាច់ស្រឡះពីគណបក្សសង្គ្រោះជាតិ។ ធ្លាប់មានការយល់ច្រឡំកាលពីពេលមុន។ គណបក្សសង្គ្រោះជាតិមិនបានទទួលប្រាក់ពីអង្គការនេះទេ។ យើងគ្មានទំនាក់ទំនងនឹងគ្នាឡើយ"។

លោកបានបន្ថែមថា "ពួកគាត់រស់នៅក្នុងប្រទេសប្រជាធិបតេយ្យនៅអាមេរិក ហេតុដូច្នេះពួកគាត់អាចធ្វើអ្វីក៏បានតាមចិត្តចង់ក្រោមច្បាប់សហរដ្ឋអាមេរិក។ ពួកគាត់មួយចំនួន គឺជាអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ ប៉ុន្តែយើងមានអ្នកគាំទ្ររាប់មិនអស់ ហើយមិនអាចបញ្ជាឱ្យពួកគាត់ធ្វើរឿងនេះរឿងនោះបានឡើយ ជាពិសេសនៅពេលពួក-គាត់នៅក្រៅប្រទេស"៕

**ស៊ុយ ឈាង**




## CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវ៉េយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ

- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ

- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- រ៉ៃកឺខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com

សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង



# Businesses for Sale

Ayer/Asian grocery , lottery, beer wine doing $800,000/yr.
Lawrence/Laundromat with income property price $529,000
Dracut/Convenience, beer& wine lottery Keno price $139,000
Brockton/Meat market & grocery, lottery doing $900,000/yr

If you want to sell your business call us 508-962-2589
email: leebrokers@gmail.com
Website: www.leebrokers.biz
Leebrokers MIng 5089622589



**Your classify ad is here for only $50 per month**

ពាណិជ្ជកម្មរបស់អ្នកនៅទីនេះ

ចំណាយចំណាយត្រឹមតែ

**$50** ក្នុង១ខែ

*CALL: 978.677.7163*

*EMAIL: SOBENPIN@KHMERPOST.US*



**បន្ថយចំណាយថ្លៃភ្លើង និងហ្គាស**

ខែរងាជិតមកដល់ចំណាយថ្លៃភ្លើង និងហ្គាស និងឡើងថ្លៃគួរឱ្យបារម្ភ -ចង់បញ្ចុះតម្លៃពី២០-៤០%

សូមទូរស័ព្ទមក

978-942-1641

# គ្រាន់តែទទួលទាន សណ្តែកដីជាប្រចាំ ក៏អាចកាត់ បន្ថយជំងឺទឹកនោមផ្អែម

សណ្តែកដី គឺគ្រាប់ធុញ្ញជាតិមួយប្រភេទដែលមានប្រយោជន៍ណាស់ដល់សុខភាពយើង។ វាអាចជួយព្យាបាលជម្ងឺ បានមួយចំនួនផងដែរ។ នៅក្នុងសណ្តែកដីផ្ទុកទៅដោយសារធាតុជំនួយដល់រាងកាយដូចជា ជាតិខ្លាញ់ វីតាមីន ជាតិ Fiber និងធាតុការពារអុកស៊ីតកម្មដែលអាចជួយដល់ប្រព័ន្ធការពាររាងកាយ។ តាមការសិក្សាស្រាវជ្រាវបានអោយដឹងថា ការទទួលទានសណ្តែកដីត្រឹមតែ១០ក្រាមជារៀងរាល់ថ្ងៃ អាចធ្វើអោយយើងកាត់បន្ថយពី ការកើតជម្ងឺមួយចំនួនដូចជា ជម្ងឺផ្លូវដង្ហើម ជម្ងឺទឹកនោមផ្អែម មហារីក និងជម្ងឺសរសៃឈាមបេះដូង។



អ្នកវិទ្យាសាស្ត្រនៅរដ្ឋ Harvest បានធ្វើការអង្កេតលើមនុស្សចំនួន៦០០០នាក់ ដែលកើតជម្ងឺទឹកនោមផ្អែម២ប្រភេទ ដែលបណ្តាលអោយអត្រាការកើតមានជម្ងឺគាំងបេះដូងខ្ពស់។ នៅពេលអ្នកទាំងនោះបានទទួលទានសណ្តែកដីជារៀងរាល់ថ្ងៃភាគរយដែលអោយកើតជម្ងឺគាំងបេះដូងបន្ថយដល់៤៤%។

សរុបមកសណ្តែកដីមានផ្ទុកសារធាតុចញ្ចឹមជាច្រើនដូចជា វីតាមីន ខ្លាញ់ ជាតិ Fiber និងធាតុការពារអុកស៊ីតកម្ម ដែលវាអាចជួយធ្វើអោយយើងរស់បានយូរជាងមុន ពីព្រោះវាជួយដល់ប្រព័ន្ធការពាររាងកាយរបស់យើង៕



# ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

**ហេតុដែលនាំឲ្យបក្សប្រជាជនគម្រាមកំហែង ក្នុងបញ្ហាព្រំដែនខ្មែរវៀតណាម**

ក្នុងសន្ធិសញ្ញាបំពេញបន្ថែមក្នុងឆ្នាំ២០០៥ គណបក្សប្រជាជនបានធ្វើការគម្រាមកំហែងយ៉ាងខ្លាំងដល់ជនណាដែលរារាំង មានចាប់សកម្មជនខ្លះដាក់ពន្ធនាគារ ពិសេសគម្រាមដល់ស្ថាប័នព្រះមហាក្សត្របើមិនព្រមចុះព្រះហស្តលេខា។ នេះជាការបញ្ជារបស់វៀតណាមឲ្យកូនចៅរបស់ខ្លួនគឺបក្សប្រជាជនធ្វើឲ្យបានសម្រេច ដើម្បីធ្វើឲ្យសន្ធិសញ្ញាខុសច្បាប់ទាំងអស់ស្របច្បាប់។ វៀតណាមបានដឹងច្បាស់ណាស់ បើមិនធ្វើសន្ធិសញ្ញាបំពេញបន្ថែមនេះទេ សន្ធិសញ្ញាទាំងអស់នឹងទៅជាមោឃៈមានបញ្ហាទឹកដីជាដើមក្រោយពីកិច្ចព្រមព្រៀងសន្តិភាពឆ្នាំ១៩៩១ ព្រោះវៀតណាមខ្លួនឯងក៏បានចុះហត្ថលេខាដែរ។ បក្សប្រជាជនបានធ្វើតាមបញ្ជាបរទេស តើត្រូវចាត់ទុកបក្សប្រជានជាបក្សបែបណា?

ជាថ្មីទៀត ការគម្រាមកំហែងរបស់បក្សប្រជាជនក្នុងបញ្ហាព្រំដែនខ្មែរវៀតណាមក្នុងពេលនេះក៏មិនខុសគ្នាពីលក្ខណៈដូចខាងលើនេះដែរ បានចាប់សកម្មជនដាក់គុកជាពិសេសគណបក្សសង្គ្រោះជាតិ ដោយបទរិះគន់បក្សប្រជាជនមានរិះគន់ពីផែនទីជាដើម ដោយគម្រាមថាបើជនណាចោទបក្សប្រជាជនប្រើផែនទីក្លែងក្លាយនឹងត្រូវមានទោស។ វៀតណាមមានការបារម្ភយ៉ាងខ្លាំងក្រែងអាណត្តិទី៦បក្សប្រជាជនមិនបានកាន់អំណាច ដូច្នេះត្រូវជម្រុញបក្សប្រជាជនឲ្យបោះបង្គោលព្រំដែនខ្មែរវៀតណាមឲ្យរួចឆាប់ ប្រសិនបើបក្សដទៃឡើងកាន់អំណាច ខ្លួនបានបោះរួចហើយជាមួយសន្ធិសញ្ញាបំពេញបន្ថែម។ បើការគម្រាមកំហែងនេះ ដោយធ្វើតាមបំណងវៀតណាមបែបនេះ ជាអំពើគួរឲ្យស្តាយ។

ខ្មែរនិងខ្មែរត្រូវតែរួមសាមគ្គីគ្នាឲ្យមានឯកភាពជាតិការពារទឹកដីរបស់ខ្លួន ព្រោះទឹកដីជារបស់ខ្មែរទាំងអស់គ្នា។ ក្នុងន័យនេះ មិនត្រូវគម្រាមកំហែងពលរដ្ឋដោយយកតុលាការឧបករណ៍ ទោះបីពលរដ្ឋមានយោបល់ផ្ទុយពីខ្លួនក៏ដោយ៕

វត្តខ្មែរកាណាដាថ្ងៃ១៥,កញ្ញា២០១៥;www.hoksavann.org;savannhok@yahoo.com

យើងខ្ញុំយកចិត្តទុកដាក់ដើម្បីឲ្យលោកអ្នកញញឹម។
*លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់!*





លោកអ្នកទទួលបានអត្ថប្រយោជន៍ទាំងអស់របស់លោកអ្នកនៅក្នុងកម្មវិធីស្តង់ដារ **MassHealth** និងកម្មវិធី **Medicare** រួមទាំងសេវាកម្មជាច្រើនទៀត។

- លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យ ដោយមិនបង់ប្រាក់ ដែលរួមមាន៖ *
  - ពិគ្រោះយោបល់នៅការិយាល័យ និងសម្អាតធ្មេញ
  - ដាក់ក្រាសធ្មេញទាំងមូលនិងដោយផ្នែក
  - ប៉ះធ្មេញ
  - ដាំធ្មេញ
- ចំណាយបដិភាគ $0 សម្រាប់គ្រប់សេវាកម្ម
- ប័ណ្ណ លោកអ្នកមានសុខភាពល្អ សម្រាប់ទិញទំនិញពាក់ព័ន្ធនឹងសុខភាពដែលមិនមានវេជ្ជបញ្ជា (រហូតដល់ $140ក្នុងមួយឆ្នាំ / $35 ក្នុងមួយត្រីមាស) *
- សេវាកម្មដឹកសមាជិកទៅកាន់និងមកពីកន្លែងណាត់ជួប *
- អាចហៅទូរស័ព្ទទៅកាន់សមាជិកក្រុមការងារនៃគម្រោង SWH បាន 24/7

SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅ:
**1-888-566-3526**(ខ្សែទូរស័ព្ទឥតគិតថ្លៃ) **TTY/TDD:711**
**www.seniorwholehealth.com/SNP**
យើងខ្ញុំបើកដំណើរការចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ ប្រាំពីរ (7) ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើលោកអ្នកមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធីស្តង់ដារ MassHealth ក៏ប៉ុន្តែមិនមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធី Medicare ផ្នែក A និង/ឬក៏ផ្នែក B លោកអ្នកប្រហែលជា អាចចុះឈ្មោះនៅក្នុងកម្មវិធីជម្រើសថែទាំសុខភាពមនុស្សចាស់ MassHealth Senior Care Options (SCO) របស់យើងខ្ញុំបាន។
លោកអ្នកដែលឆ្លើយតបទៅនឹងលក្ខខណ្ឌខាងលើអាចចុះឈ្មោះបានគ្រប់ពេលវេលារៀងរាល់ឆ្នាំ។

** លក្ខខណ្ឌកំណត់អាចត្រូវបានអនុវត្ត*

គម្រោងសុខភាពទាំងមូលរបស់មនុស្សចាស់ គឺជាគម្រោងថែទាំសុខភាព HMO SNP ដែលមានការសម្របសម្រួល និងកិច្ចសន្យាផ្តល់- ទទួលសេវាកម្មនៃកម្មវិធី Medicare និងកិច្ចសន្យាជាមួយ Commonwealth of Massachusetts/កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះធ្វើឡើងដោយស្ម័គ្រចិត្ត និងអាស្រ័យទៅលើការបន្តកិច្ចសន្យាប្រចាំឆ្នាំ។ ព័ត៌មានអំពីអត្ថប្រយោជន៍នៅក្នុងឯកសារនេះ គឺជាសេចក្តីសង្ខេបមួយ មិនមែនជាសេចក្តីពិពណ៌នាលម្អិតអំពីអត្ថប្រយោជន៍ទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យគម្រោង។ លក្ខខណ្ឌកំណត់ ប្រាក់បដិភាគ ឬក៏លក្ខខណ្ឌកម្រិតផ្សេងៗទៀតអាចត្រូវបានអនុវត្ត។អត្ថប្រយោជន៍ រូបមន្ត បណ្តាញអ្នកផ្តល់សេវាកម្ម និងបណ្តាញឱសថស្ថាន អាចត្រូវបានផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករា នៃឆ្នាំនីមួយៗ។ លោកអ្នកត្រូវតែបន្តបង់បុព្វលាភផ្នែក B របស់លោកអ្នក ប្រសិនបើបុព្វលាភនោះមិនកំពុងត្រូវបានបង់ដោយភាគីណាមួយផ្សេងទៀតនៅឡើយទេ។ គម្រោងនេះត្រូវបានបង្កើតឡើងសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានជំនួយវេជ្ជសាស្ត្រដែលទទួលបានទាំងពីរដ្ឋ និងកម្មវិធី Medicare។
H2224_2015_104kh Accepted 12/7/2014

តមកទំព័រទី ១៤

## កម្ពុជាជាប់ឈ្មោះជាប្រទេសដែល...

៤៥ភាគរយនៃការបាត់បង់នោះបានកើតឡើងនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចដែលរដ្ឋាភិបាលជួលឱ្យក្រុមហ៊ុនឯកជនសម្រាប់ប្រតិបត្តិការកសិឧស្សាហកម្មដែលភាគច្រើនជាចម្ការកៅស៊ូ។

រដ្ឋាភិបាលនឹងមិនបញ្ចេញបញ្ជីពិស្តារនៃដីសម្បទានសេដ្ឋកិច្ចសកម្មទាំងអស់ និងព្រំប្រទល់នីមួយៗឡើយ។ អង្គការលីកាដូបញ្ជាក់ពីបញ្ជីមួយដែលផ្អែកលើកំណត់ត្រាបន្តិចម្តងៗដែលរដ្ឋាភិបាលបញ្ចេញ និងប្រភពផ្ទាល់ខ្លួនរបស់រដ្ឋាភិបាល។

លោក ម៉ាតស៊ូ ពេឡឺរីន (Mathieu Pellerin) អ្នកប្រឹក្សាយោបល់របស់អង្គការលីកាដូ ផ្នែកបញ្ហាដីធ្លី បានមានប្រសាសន៍ថា ដោយសារតែមានការរឹតបន្តឹងក្នុងប្រមូលទិន្នន័យតួលេខសម្រាប់ការបាត់បង់ព្រៃឈើនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចជាចំណែកនៃការបាត់បង់ព្រៃឈើសរុបនៅក្នុងឆ្នាំ២០១៤ ឱ្យពោលគឺ៤៤.៥ភាគរយ គឺប្រហែលជាតួលេខមិនច្រើនទេ។

លោកមានប្រសាសន៍ថា "តួលេខនេះនឹងកើនឡើងដល់យ៉ាងតិច៥០ភាគរយ ប្រសិនបើយើងបន្ថែមចម្ការដែលឃើញយ៉ាងច្បាស់ថា ហួសពីព្រំប្រទល់របស់វា និងប្រសិនបើយើងមានរបាយការណ៍ស្តីពីដីសម្បទានសេដ្ឋកិច្ចសេសសល់មួយចំនួនដែលយើងគ្មាន"។

តាមពិតផែនទីស្តីពីការបាត់បង់ព្រៃឈើពិភពលោកដែលត្រូវបានធ្វើបច្ចុប្បន្នភាពរបស់សាកលវិទ្យាល័យម៉ារីលែនបានបង្ហាញថា កម្ពុជាកំពុងបន្តបាត់បង់ព្រៃឈើយ៉ាងច្រើននិងយ៉ាងឆាប់រហ័សនៅក្នុង និងជុំវិញតំបន់ដីសម្បទានសេដ្ឋកិច្ចក្នុងនោះមានខ្លះនៅក្នុងតំបន់ការពារ។ ផែនទីនេះបង្ហាញពីការបាត់បង់ដ៏គួរឱ្យចាប់អារម្មណ៍បំផុតមួយចំនួននៅក្នុង និងជុំវិញតំបន់ដីសម្បទានសេដ្ឋកិច្ចដែលស្ថិតក្នុងដែនជម្រកសត្វព្រៃបឹងពែរភាគខាងត្បូងខេត្តព្រះវិហារ និងក្នុងតំបន់អភិរក្សជីវៈចម្រុះស្នួលសីមា ដែលស្ថិតនៅតាមបណ្តោយព្រំប្រទល់ខេត្តក្រចេះ និងខេត្តមណ្ឌលគិរី។

រដ្ឋាភិបាលអះអាងថា ខ្លួនផ្តល់ដីសម្បទានសេដ្ឋកិច្ចណាដែលមានព្រៃរេចរិលត្រូវកាប់បំផ្លាញដោយអ្នកតាំងទីលំនៅថ្មី អ្នកបរបាញ់សត្វ និងអ្នកកាប់ឈើខុសច្បាប់រួចហើយប៉ុណ្ណោះ។ ប៉ុន្តែក្នុងចំណោមតំបន់ការពារនៅកម្ពុជាគ្មានតំបន់ណាមួយមានផែនទីបញ្ជាក់ទីតាំងឱ្យបានត្រឹមត្រូវដែលអាចបង្ហាញថា? កន្លែងណាជាកន្លែងដែលមានការកាប់បំផ្លាញព្រៃឈើនោះឡើយ ហើយដីសម្បទានសេដ្ឋកិច្ចមួយចំនួនត្រូវបានផ្តល់មុនពេលមានការវាយតម្លៃពីផលប៉ះពាល់បរិស្ថានដែលច្បាប់តម្រូវ។

ទិន្នន័យផ្កាយរណបក្នុងពេលថ្មីៗនេះប្រមូលដោយអង្គការណាសាដែលវាស់វែងថ្មីងថ្លែងអំពីការបំភាយកាបូនចេញពីការឆេះព្រៃបង្ហាញថាតាមពិតទៅដីសម្បទានសេដ្ឋកិច្ចត្រួតស៊ីគ្នានឹងដីព្រៃរេចរិលតិចតួចតួចមួយចំនួនក្នុងប្រទេសកម្ពុជា។

កាលពីខែកក្កដា អង្គការសិទ្ធិបរិស្ថានឈ្មោះនិន្នាការព្រៃឈើ (Forest Trends) ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិកបានលើកឡើងថាខ្លួនបានពិនិត្យមើលទិន្នន័យឆេះព្រៃរបស់អង្គការណាសា សម្រាប់រដូវប្រាំងចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៣នៅកម្ពុជា។ អង្គការនេះបានលើកឡើងបន្តថា ការបំភាយកាបូនចេញពីព្រៃស្រោងដែលត្រូវបានកាប់បំផ្លាញនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចគឺខ្ពស់ជាងការបំភាយចេញពីព្រៃដែលនៅខាងក្រៅតំបន់ដីសម្បទានសេដ្ឋកិច្ច១០ដង "ដោយវាបញ្ជាក់ឱ្យឃើញថា ក្រុមហ៊ុនកំពុងតែផ្តោតទៅលើព្រៃដែលមានឈើដ៏ចំណាស់បំផុតនិងមានតម្លៃបំផុតដែលភាគច្រើនស្ថិតនៅក្នុងដីព្រៃរបស់រដ្ឋ"។

បណ្តាអង្គការសិទ្ធិមនុស្សដែលរួមមានដូចជាអង្គការលីកាដូជាដើមបានចោទប្រកាន់ជាយូរមកហើយថា រដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចយ៉ាងច្រើនជាវិធីសាស្ត្រគេចវេះពីបម្រាមផ្លូវការក្នុងគោលបំណងកាប់ឈើក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច។ ដោយរងសម្ពាធយ៉ាងខ្លាំងពីសំណាក់អ្នករិះគន់ទាំងក្នុងស្រុក និងក្រៅប្រទេសរដ្ឋាភិបាលបានផ្អាកការផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មីកាលពីពាក់កណ្តាលឆ្នាំ២០១២ តែទោះជាយ៉ាងណាសម្បទានដីសេដ្ឋកិច្ចចំនួន៣០ត្រូវបានផ្តល់ឱ្យនៅប៉ុន្មានខែក្រោយមកទៀត។

ទោះបីជាកម្ពុជាជាប់ចំណាត់ថ្នាក់កំពូលនៅក្នុងបញ្ជីនៃប្រទេសដែលមានកំណើនកាប់បំផ្លាញព្រៃឈើលឿនបំផុតក្នុងរយៈពេល១៤ឆ្នាំកន្លងមកនេះក្តីតែការបាត់បង់គម្របព្រៃឈើពីមួយឆ្នាំទៅមួយឆ្នាំរបស់កម្ពុជា? តាមពិតទៅបានថយចុះនៅក្នុងឆ្នាំ២០១៤។ លោក ម៉ាតស៊ូ ពេឡឺរីន អ្នកផ្តល់ប្រឹក្សាយោបល់របស់អង្គការលីកាដូបានលើកឡើងថា ការផ្អាកផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មីកាលពីឆ្នាំ២០១២ អាចនឹងមានលទ្ធផលល្អនៅទីបំផុត ប៉ុន្តែលោកបានបន្ថែមថា វាលឿនពេកហើយដែលនិយាយថា? តើកម្ពុជាចាប់ផ្តើមមានភាពប្រសើរឡើង ឬយ៉ាងណានោះ។

លោកមានប្រសាសន៍ថា "ការផ្អាកផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មី បានចាប់ផ្តើមមានប្រសិទ្ធភាពក្នុងឆ្នាំ២០១៤ ចំណែកឯនៅក្នុងឆ្នាំមុនៗដីសម្បទានសេដ្ឋកិច្ចថ្មីៗត្រូវបានផ្តល់នៅជិតពេលផ្អាក ឬក្រោយការផ្អាក"។

យោងតាមវិទ្យាស្ថានធនធានពិភពលោកបានឱ្យដឹងថា ពិភពលោកបានបាត់បង់គម្របព្រៃឈើជាង១៨លានហិកតាក្នុងឆ្នាំ២០១៤ ដែលស្មើនឹង២ដងនៃផ្ទៃដីរបស់ប្រទេសព័រទុយហ្គាល់៕ **សុខុម និង ស៊ុយឈាង**

Continued from page 14

## Cambodia Sees World's Fastest...

Indeed, the University of Maryland's updated map of global forest loss shows much of Cambodia's losses continuing to take place in-and immediately around-ELCs, some of them inside the country's protected areas. The map shows some of the most concentrated losses on and around ELCs inside the BengPer Wildlife Sanctuary in southern PreahVihear province and the SnoulSeima Biodiversity Conservation Area along the border of Kratie and Mondolkiri provinces.

